## សាររពីអ្នកគ្រប់គ្រង (នាយកប្រតិបត្តិ)

របាយការណ៍នេះ បានបង្កើតឡើង និងបង្ហាញពីការអនុវត្តគម្រោងចាប់ពីឆ្នាំ ២០១៩ ដោយក្រុមអ្នកគ្រប់គ្រង និងបុគ្គលិកបច្ចេកទេសរបស់ EPDO ដែលមានទីតាំងនៅភូមិក្បាលហុង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ពោធិ៍សាត់។ រឿងរ៉ាវដែលបានសរសេរនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១៩ ដែលបានបន្លិចផលប៉ះពាល់នៃកម្មវិធី អង្គការ EPDO ក្នុងការធ្វើការជាមួយប្រជាជននៅតាមជនបទដែលយើងបម្រើ។ នៅក្នុងឯកសារកម្មវិធីអង្គការ EPDO



២០១៩ ការប្រែប្រួលអាកាសធាតុគឺបញ្ហាបល្អិតល្អន់ចូលទៅក្នុងកម្មវិធីរួមមួយនឹងគោលបំណងនៃគម្រោងនិមួយៗផងដែរ។ ផ្តល់សិទ្ធិអំណាចដល់ប្រជាជននៅតាមជនបទដែលរងផលប៉ះពាល់បំផុត ដើម្បីក្លាយជាអ្នកយល់ដឹងកាន់តែខ្លាំងឡើង អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងដើម្បីរកវិធីក្នុងការកាត់បន្ថយហានិភ័យទាំងនោះ។ គំនិតច្នៃប្រឌិតថ្មីមួយទៀតគឺការផ្តោតអារម្មណ៍ ស្តីពីការលើកកម្ពស់ការ ផ្តល់សិទ្ធិអំណាចដល់មេដឹកនាំសំខាន់ៗក្នុងតំបន់រួមមាន គណៈកម្មាធិការអភិវឌ្ឍន៍ (VDCs) និងសហគមន៍កសិកម្ម (ACs) ផ្តោតអារម្មណ៍ជាច្រើននៅលើកម្មវិធីអង្គការ EPDO ពីព្រោះយើងមានជំនឿថា មេដឹកនាំក្នុងតំបន់ដែលបានផ្តល់អំណាច នឹងមានគណនេយ្យភាព និងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព នៃកម្មវិធីនេះ។

ការពង្រឹងសមត្ថភាពដល់ VDCs ភ្នាក់ងារសុខភាពសត្វភូមិ(VAHWs) សហគមន៍កសិកម្ម(ACs)អ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៏ បានកើនឡើងបន្តិចម្តងៗ តាមរយៈការអន្តរាគមន៍របស់យើង។ អង្គការ EPDO បានបន្តផ្តល់ការយកចិត្តទុកដាក់ដល់គ្រួសារដែលងាយរងគ្រោះជាក់លាក់បំផុតនៅក្នុងសហគមន៍គោលដៅរួមទាំងស្ត្រីជាមេគ្រួសារ និងប្រជាជនទូទៅនៅក្នុងសហគមន៏ដែលយើងកំពុងបម្រើផងដែរ។

យើងបានផ្លាស់ប្តូរវិធីសាស្រ្តរបស់យើងធ្វើការជាមួយនឹងអ្នកដែលនៅក្នុងភាពងាយរងគ្រោះបំផុត ពីការគាំទ្រចំពោះបុគ្គល ឆ្ពោះទៅរកក្រុមពួកគេនៅក្នុងគោលបំណងដើម្បីគ្របដណ្តប់គ្រួសារជាដៃគូបន្ថែមទៀត។ ជាលទ្ធផលយើងអាចគាំទ្រ បានល្អប្រសើរជាងមុន ដោយភ្ជាប់រវាង VDCs និងអ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៍ឲ្យពួកគេធ្វើការជាមួយគ្នា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអ្នកដែលងាយរងគ្រោះ តាមរយៈការពង្រឹងសមត្ថភាព និងការគាំទ្រនានាបានធ្វើឲ្យពួកគេ មានការផ្លាស់ប្រែទាំងចំណេះដឹង ជំនាញ អាកប្បកិរិយា និងជីវភាពរបស់ ប្រសើរជាងមុន។

ក្នុងនាមអង្គការEPDO និងក្នុងនាមខ្ញុំផ្ទាល់ សូមថ្លែងអំណគុណដល់ រាជរដ្ឋាភិបាលកម្ពុជា ដៃគូផ្តល់មូលនិធិរបស់យើងដែលបានគាំទ្រ បានធ្វើឱ្យអង្គការ EPDO អាចបម្រើដល់សហគមន៏គោលដៅទទួលបានលទ្ធផលគួរជាទីមោទនៈរហូតមកដល់ពេលនេះ។ វាជាការសំខាន់ដើម្បីចងចាំថា សមិទ្ធផលទាំងនេះ មិនអាចធ្វើបានទេប្រសិនបើគ្មានការគាំទ្រ ពីសំណាក់ភ្នាក់ងារផ្តល់ជំនួយ អង្គការជាតិ អន្តរជាតិ រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ជាពិសេសដល់ដៃគូអភិវឌ្ឍន៍របស់យើងទាំងអស់រួមទាំងសហគមន៍គោលដៅក្នុងតំបន់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការសហការ និងការគាំទ្រល្អ។

ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់មិត្តរួមការងាររបស់ខ្ញុំទាំងអស់សម្រាប់អង្គការ EPDO ដែលមានស្មារតីធ្វើការបម្រើផលប្រយោជន៏ដល់សហគមន៏ដៃគូរបស់យើង ដោយសេចក្តីស្រឡាញ់ ការគោរពវិជ្ជាជីវៈការងារ មានតម្លាភាព

គណនេយ្យភាព និងការងារជាក្រុម ដែលបានធ្វើឲ្យមានការកើតឡើងនូវសមិទ្ធផលទាំងអស់របស់ឆ្នាំ២០១៩នេះ ខ្ញុំសូមបញ្ចប់សាររបស់ខ្ញុំតែត្រឹមនេះ។

សង្ឃឹមថា EPDO នឹងទទួលបានការគាំទ្រជាបន្ត ពីអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដែលមិនអាចកាត់ថ្លៃបាន ដើម្បីរួមគ្នាកសាង និងការពារសមិទ្ធផលបច្ចុប្បន្ន និងអនាគត និងដើម្បីបង្កើតវិធីសាស្ត្រ ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជារាប់ពាន់នាក់ជួបការលំបាករួមទាំងស្រ្តី និងកុមារដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាលផងដែរ។

## អារម្ភណ៏កថា

សមិទ្ធផលទាំងនេះនឹងមិនអាចទៅរួចទេ បើគ្មានការប្តេជ្ញាចិត្តដ៏អស្ចារ្យរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង សមាជិកបុគ្គលិក និងការគាំទ្រប្រភពថវិកាពីភ្នាក់ងារផ្តល់ជំនួយនានា។

សម្រាប់ឆ្នាំ ២០១៩ សមិទ្ធផលទាំងឡាយត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងធំធេងពីដៃគូផ្តល់ជំនួយដូចជា៖ Australian Catholic Relief / Caritas Australia (ACR/ CA) កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធនទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តពោធិ៍សាត់ និងកម្មវិធីជំរុញផលិតកម្មស្បៀប(BFP) គាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ។

យើងសូមថ្លែងអំណរគុណចំពោះបុគ្គលិកបច្ចេកទេសទាំងអស់ សម្រាប់ការប្រមូលផ្តុំព័ត៌មានពីវិស័យនេះ ហើយដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការងារដ៏លំបាកបំផុតរបស់ពួកគេ និងដៃគូផ្តល់ជំនួយដែលតែងតែគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ EPDO ជាពិសេសដល់អ្នកទទួលផលដែលបានចូលរួមក្នុងកម្មវិធី ដើម្បីកែលំអជីវភាពរស់នៅ និងបច្ចេកវិជ្ជាថ្មី។ សម្លេងរបស់ពួកគេត្រូវបានឮ អ្នកក្រក៏មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តការចូលរួមធ្វើផែនការ ការចូលរួមអនុវត្តគម្រោង និងការចូលរួមតាមដានត្រួតពិនិត្យ និងកែលម្អរកម្មវិធីទាំងអស់គ្នា ហើយនេះគឺជាបេសកកម្ម និងគោលដៅរបស់យើង។

ចុងក្រោយយើងសូមថ្លែងអំណរគុណចំពោះ អង្គការដៃគូ ម្ចាស់ជំនួយ ស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងប្រជាពលរដ្ឋ សម្រាប់កិច្ចសហការល្អរបស់ពួកគេ និងជោគជ័យដ៏អស្ចារ្យដែលនឹងបន្ត។

## ប្រវត្តិអង្គការ អភិវឌ្ឍន៍ និង ការពារបរិស្ថាន

អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន EPDOគឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមិនពាក់ព័ន្ធនឹងនយោបាយ ឬគណបក្សណាមួយឡើយ។ អង្គការ EPDO បានបង្កើតឡើងនៅដើមឆ្នាំ១៩៩៨ ដើម្បីធ្វើការទៅលើការការពារបរិស្ថាន ការអភិរក្សអភិវឌ្ឍន៏ធនធានធម្មជាតិ លើកកំពស់នូវជីវភាពប្រចាំថ្ងៃ ការឆ្លើយតបទៅនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ។ EPDO បានចុះឈ្មោះ នៅក្រសួងមហាផ្ទៃ តាមលិខិតលេខ ៤៩៤សជណ ចុះថ្ងៃ ទី៦ ខែកក្កដាឆ្នាំ ១៩៩៨។

អង្គការEPDOមានបទពិសោធន៍២០ឆ្នាំក្នុងប្រទេសកម្ពុជាក្នុងការអនុវត្តកម្មវិធី គ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន បន្សាំការប្រែប្រួលអាកាសធាតុ លើកកំពស់នូវជីវរស់នៅរបស់

ប្រជាពលរដ្ឋតាមរយៈការបញ្ចូលបច្ចេកវិជ្ជាវិស័យកសិកម្ម (ដំណាំស្រូវ ចិញ្ចឹមសត្វ វារីវប្បកម្មនិងដាំបន្លែ) ទឹកស្អាតអនាម័យ ការអប់រំសិទ្ធិកុមារ និងអភិបាលកិច្ចល្អ។

## ទស្សនៈវិស័យ

សង្គមមួយដែលពលរដ្ឋកម្ពុជាគ្រប់រូបរស់នៅដោយមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពល្អប្រសើរ

## បេសកកម្ម

រួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា ដែលមានការរស់នៅក្នុងបរិយាកាសល្អ តាមរយៈការកសាងសមត្ថភាព និងពង្រឹងភាពអង់អាចពួកគេ ដើម្បីធ្វើអោយប្រសើរឡើងនូវជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលបង្កើតអោយមានកំណើនប្រាក់ចំណូល។

## គុណតំលៃ

ការចូលរួម តម្លាភាព ផលប៉ះពាល់ បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង

### ការចូលរួម

គោលការណ៍ការងាររបស់ EPDO ធានាអោយមានការចូលរួមពីអ្នកភូមិ និងអាជ្ញាធរមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងធ្វើអោយប្រសើរឡើងនូវលទ្ធភាព និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។ បុគ្គលិក EPDO ត្រូវពិគ្រោះជាមួយអ្នកពាក់ព័ន្ធជាច្រើន ក្នុងការរៀបចំ និង ការអនុវត្តកម្មវិធី ដើម្បីជួយធានាថា តម្រូវការរបស់ពួកគេត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធី។

### តម្លាភាព

បុគ្គលិក EPDO ទទួលស្គាល់តម្លៃនៃតម្លាភាពដែលជាប្រតិបត្តិការតាមវិធីសាស្រ្តមួយដែលអនុញ្ញាតឱ្យអ្នកដទៃពិនិត្យមើលថាតើសកម្មភាពអ្វីខ្លះត្រូវបានអនុវត្ត។ EPDO ជឿជាក់ថាតម្លាភាពគឺមានសារៈសំខាន់ណាស់សម្រាប់ការផ្តល់កម្មវិធីដែលទទួលបានជោគជ័យ ទាំងការគ្រប់គ្រង និងការអនុវត្ត។

### ផលប៉ះពាល់

EPDO ឲ្យតំលៃលើគណនេយ្យភាព និងការតាមដានការងាររបស់ខ្លួនដើម្បីធានានូវភាពប្រសើរឡើងវិជ្ជមានក្នុងជីវភាពរស់នៅ និងសហគមន៍ដែលយើងធ្វើការជាមួយ។

### បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង

បុគ្គលិករបស់ EPDO ត្រូវបានចុះមូលដ្ឋានជាមួយសហគមន៍ ចែករំលែក និងរៀនសូត្រក្នុងចំណោមអ្នកពាក់ព័ន្ធ ដែលពួកគេធ្វើការជាមួយ ហើយនឹងបង្កើនភាពជឿជាក់ គោរពគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងបង្កើនចំណេះដឹង តាមរយៈការអនុវត្តសកម្មភាពនៅមូលដ្ឋាន។

## គោលដៅ

ដើម្បីលើកកំពស់សិទ្ធអំណាចដល់សហគមន៍ ក្នុងការគ្រប់គ្រងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន និងលើកកម្ពស់គំរូនៃវិស័យកសិកម្ម និងមិនមែនកសិកម្ម ដែលធនទ្រាំនឹងអាកាសធាតុ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ តាមរយៈការអនុវត្តចម្រុះកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ។

## គោលបំណងសំខាន់ៗរបស់EPDO

- បង្កើនសមត្ថភាពសមត្ថភាពរបស់អ្នកដឹកនាំអភិវឌ្ឍ ក្នុងការសំរបសំរួលគំនិតផ្តួចផ្តើមរបស់សហគមន៍ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន។
- ពង្រីកភាពជាដៃគូនៅថ្នាក់ក្រោមជាតិ និងសហគមន៍ ដោយមានកិច្ចសហប្រតិបត្តិការពេញលេញពីស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីធានាថាការអភិវឌ្ឍន៍សហគមន៍ដោយផ្អែកលើធនធានជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- កសាងសមត្ថភាពដល់គ្រួសារក្រីក្រ និងគ្រួសារដែលងាយរងគ្រោះអំពីជំនាញ ចំណេះដឹងបច្ចេកទេសក្នុងការប្រកបមុខរបរ និងការធ្វើជំនួញ ដើម្បីធានាថា ការកែលំអជីវភាពរស់នៅ និងកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព។
- កែលម្អបច្ចេកទេស និងបច្ចេកវិជ្ជានៃវិស័យកសិកម្ម ធនទ្រាំនឹងអាកាសធាតុ ច្នៃប្រឌិតសម្រាប់ផលិតភាពការធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្មដើម្បីដោះស្រាយបញ្ហាប្រឈមទីផ្សារ និងកសាងលក្ខខណ្ឌទីផ្សារអំណោយផលក្នុងភាពជាដៃគូពាណិជ្ជកម្ម។

## យុទ្ធសាស្ត្រ

- ពង្រឹងកម្មវិធីដែលរៀបចំឡើងដើម្បីលើកកម្ពស់សន្តិសុខស្បៀងសម្រាប់ទាំងអស់គ្នា
- ស្វែងរកការគាំទ្រដើម្បីឲ្យមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- បង្កើនសមត្ថភាពសហគមន៍ និង រដ្ឋបាលមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ តាមរយៈការពង្រឹងភាពជាដៃគូ និងដំណើរការសង្គ្រោះបន្ទាន់។
- គាំទ្រ និងអប់រំ សកម្មភាពទឹកស្អាត និងអនាម័យសម្រាប់ទាំងអស់គ្នា។
- ពង្រឹងប្រព័ន្ធផ្ទៃក្នុង ដំណើរការ និងការរៀបចំកម្មវិធី។

## ក្រុមគោលដៅ

ដោយផ្អែកលើបេសកកម្មរបស់ខ្លួន EPDO នឹងផ្តល់នូវសកម្មភាពអាទិភាពដល់ប្រជាជនកម្ពុជាដែលរស់នៅក្នុងតំបន់គោលដៅរបស់ខ្លួន ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ឱកាសជីវភាពដែលមាននិរន្តរភាពសម្រាប់ជនក្រីក្រ និងប្រជាពលរដ្ឋទូទៅរួមមាន សមាជិកសហគមន៍ ស្ត្រី យុវជន កុមារ ចាស់ជរា ជនពិការ កុមារកំព្រា និងងាយរងគ្រោះ ក្រុមជួយខ្លួនឯង ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ សហគមន៍កសិកម្ម អាជ្ញាធរមូលដ្ឋានភូមិ ឃុំ និងស្រុក។ រចនាសម្ព័ននៃកម្មវិធីដែលអនុវត្តដោយ EPDO គឺថាបន្ទាប់ពីបញ្ចប់កម្មវិធីនីមួយៗមនុស្សដែលមានគោលដៅអាចរស់នៅប្រកបដោយចីរភាពដោយគ្មានការគាំទ្រពី EPDO ។

ផ្តោតលើវិស័យកម្មវិធី / គម្រោង:

- វិស័យកសិកម្មរួមមាន៖ ដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្វ វារីវប្បកម្មនិងការគ្រប់គ្រងធនធានធម្មជាតិ

- ទឹកស្អាត និងអនាម័យ
- គ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

## បុគ្គលិក

បច្ចុប្បន្ន EPDO មានកម្លាំងបុគ្គលិកចំនួន ១៩នាក់ (ស្រី១០នាក់):

- នាយកប្រតិបត្តិ ១នាក់
- ប្រធានកម្មវិធី ១នាក់
- អ្នកសម្របសម្រួលគម្រោង ២នាក់ ស្រី១នាក់
- មន្ត្រីរដ្ឋបាលហិរញ្ញវត្ថុ ២នាក់ ស្រី១នាក់
- មន្ត្រីបច្ចេកទេស ៦នាក់ ស្រី៤នាក់
- មន្ត្រីគម្រោង ៦នាក់ ស្រី៣នាក់
- អ្នកសំអាត ១នាក់ ស្រី១នាក់

# គម្រោងឆ្នាំ២០១៩

## ១. គម្រោង ជំរុញផលិតកម្មមាន់

គាំទ្រថវិកាដោយ IFAD Investing in rural people

### ១.១.សេចក្តីផ្តើម:

គម្រោងជំរុញច្រវ៉ាក់ផលិតកម្មមាន់ក្នុងខេត្តពោធិ៍សាត់ គឺបាននឹងកំពុងអនុវត្តន៍ជាមួយក្រុមផលិតមាន់ចំនួន ១០កសិដ្ឋានចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ មកដល់ពេលនេះជ្រើសរើសបាន១០កសិដ្ឋានក្នុង១០ភូមិ ៧ឃុំ ក្នុងស្រុកចំនួន២ ក្នុងខេត្តពោធិ៍សាត់ ស្រុកកណ្តៀង (ភូមិបឹងក្រាញ់ ឃុំកញ្ជរ ភូមិស្តុកជុំ ឃុំកោះជុំ ភូមិវាល បាគូ បន្ទាយត្រោក ថ្មី ឃុំស្រែស្តុក ភូមិស្យា ឃុំស្យា ភូមិស្នឹងក្រោម ឃុំកណ្តៀង ស្រុកកណ្តៀង) ស្រុកភ្នំក្រវ៉ាញ (ភូមិអូរចង់ និងភូមិទួលពង្រ ឃុំចាក់ចិញ្ចៀន)។ គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដល់កសិដ្ឋានចិញ្ចឹមមាន់ និងសមាជិកក្រុមផលិតកម្មសត្វ និងការផ្សារភ្ជាប់ខ្សែសង្វាក់ផលិតកម្មទីផ្សារ។ គម្រោងនេះមានរយៈពេល១០ខែ ផ្តល់មូលនិធិដោយ IFAD និងចុះកិច្ចសន្យារវាងអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) ជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត /អនុកម្មវិធីខេត្តពោធិ៍សាត់។

តំបន់ដែលបានជ្រើសរើសទាំងនេះជាតំបន់ដែលមានសក្តានុពលសម្រាប់កសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈអាជីវកម្ម និងធ្វើការលក់បន្តទៅតំបន់ផ្សេងៗទៀត។ គម្រោងនេះមានរយៈពេល១០ខែ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ទទួលបានការគាំទ្រថវិកាពីគម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅ និងការប្រែប្រួលអាកាសធាតុ(ASPIRE) របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ចំនួន៤០.៥០០ដុល្លាគត់។

### ១.២.តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| លរ | ភូមិ | ឃុំ | ស្រុកក្រុង/ | ខេត្ត | អ្នកចូលរួមក្នុងគម្រោង | | |
|---|---|---|---|---|---|---|---|
| | | | | | គ្រួសារ | មនុស្សសរុប | ស្រី |
| ១ | បឹងក្រាញ់ | កញ្ជរ | កណ្តៀង | ពោធិ៍សាត់ | ៥៣ | ២២១ | ១៣៣ |
| ២ | ស្យា | ស្យា | កណ្តៀង | ពោធិ៍សាត់ | ៣៦ | ១៨០ | ១០៨ |
| ៣ | បាគូ | ស្រែស្តុក | កណ្តៀង | ពោធិ៍សាត់ | ៧៩ | ៣១៦ | ១៨៩ |
| ៤ | វាល | ស្រែស្តុក | កណ្តៀង | ពោធិ៍សាត់ | ៥៤ | ២១៦ | ១៣០ |
| ៥ | ថ្មី | ស្រែស្តុក | កណ្តៀង | ពោធិ៍សាត់ | ៨៤ | ៣៣៦ | ២០២ |
| ៦ | បន្ទាយត្រោក | ស្រែស្តុក | កណ្តៀង | ពោធិ៍សាត់ | ៥០ | ២១៣ | ១៣៦ |
| ៧ | ស្តុកជុំ | កោះជុំ | កណ្តៀង | ពោធិ៍សាត់ | ៣៤ | ១៧០ | ១០២ |
| ៨ | ស្ទឹងក្រោម | កណ្តៀង | កណ្តៀង | ពោធិ៍សាត់ | ៤២ | ១៦៨ | ១០១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩ | ទួលពង្រ | ចាក់ចិញ្ចៀន | ភ្នំក្រវាញ | ពោធិ៍សាត់ | ៥៨ | ២៣២ | ១៤០ |
| ១០ | អូររំចង់ | ចាក់ចិញ្ចៀន | ភ្នំក្រវាញ | ពោធិ៍សាត់ | ៥៥ | ២២០ | ១៣២ |
| **សរុ** | **១០** | **៦** | **២** | **១** | ៥៤៥ | ២.២៧២ | ១.៣៧៣ |

**គោលបំណងគម្រោង:** បង្កើតអាជីវកម្មកសិដ្ឋានចិញ្ចឹមមាន់និងកូនមាន់តាមរយៈការបង្វែរកសិករចិញ្ចឹមមាន់ខ្នាតតូចទៅជាបណ្ដុំអាជីវកម្មតាមខ្សែច្រវ៉ាក់ផលិតកម្មកូនមាន់ពូជឆ្លើយតបតម្រូវការទីផ្សារប្រកបដោយនិរន្តរភាពពេលបញ្ចប់នៃគម្រោង។

## ១.៣.លទ្ធផលសម្រេចបាន:



### ១.រៀបចំសិក្ខាសាលាចាប់ផ្ដើមការអនុវត្តន៍គម្រោងចំនួន១លើក:

សិក្ខាសាលាស្ដីពីការចាប់ផ្ដើមអនុវត្តគម្រោងនៅថ្នាក់ខេត្ត និងបង្ហាញពីសកម្មភាពគម្រោងជាមួយអ្នកពាក់ព័ន្ធសំខាន់ រួមទាំងមេដឹកនាំកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈអាជីវកម្ម និងសមាជិកអ្នកចិញ្ចឹមមាន់នៅសាលប្រជុំរបស់មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តពោធិ៍សាត់ ដោយមានអ្នកចូលរួមចំនួន៣៣ ស្រី៣នាក់។

**២.រៀបចំលក្ខន្តិកៈសហគ្រាសកសិដ្ឋានអាជីវកម្មចិញ្ចឹមមាន់ទាំងអស់ដើម្បីគ្រប់គ្រង និងការចែកបន្ត:** បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចិញ្ចឹមមាន់ជាអាជីព ដែលមានសក្ដានុពលក្លាយជាកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈអាជីវកម្ម និងសមាជិកក្រុមបាន១ច្បាប់ ព្រមទាំងបានជ្រើសរើសកសិករចិញ្ចឹមមាន់បានចំនួន២៦០នាក់ ស្រី១៤៨នាក់។

### ៣.ការបង្កើតជាកសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្មចំនួន១០៖




ជ្រើសរើកសិករសម្រាប់រៀបចំជាកសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្មបានចំនួន១០គ្រួសារ និងសមាជិកក្រុមសម្រាប់ទទួលបានកូនមាន់បន្តពីកសិដ្ឋានភ្ញាស់កូនមាន់បានចំនួន២៦០នាក់ និងរៀបចំជាក្រុមបានចំនួន១០ក្រុម ក្នុងភូមិគោលដៅទាំង១០(ភូមិបឹងក្រាញ់ ឃុំកញ្ជរ ភូមិស្អកជុំ ឃុំកោះជុំ ភូមិវាល បាគូ បន្ទាយត្រោក ថ្មី ឃុំស្រែស្អក ភូមិស្យា ឃុំស្យា ភូមិស្ទឹងក្រោម ឃុំកណ្ដៀង ស្រុកកណ្ដៀង ភូមិអូររំចង់ និងភូមិទួលពង្រ ឃុំចាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់)។

**៤.រៀបចំរចនាសម្ព័ន្ធក្រុម អាជីវកម្ម មាន់៖** រៀបចំរចនាសម្ព័ន្ធក្រុម និងអ្នកដឹកនាំអាជីវកម្មផលិតមាន់ជាមួយក្រុមអ្នកផលិត និងកំណត់ជាសហគ្រាស បានចំនួន១០ក្រុម មានគោលការណ៍ លក្ខន្តិកៈក្រុម ដោយមានអ្នកចូលរួមចំនួន២៦០នាក់ ស្រី១៤៨នាក់។

### ៥. បណ្ដុះបណ្ដាលបច្ចេកទេស ផលិតកម្មមាន់ចំនួន ១០ (២វគ្គ/ក្រុម) បណ្ដុះបណ្ដាបច្ចេកទេសស្ដីពីការចិញ្ចឹមមាន់ និងការអនុវត្តបច្ចេកទេសស្ដីពីដំណើរការនៃការប្រើប្រាស់ទូរភ្ញាស់កូនមាន់៖

▪ ផ្ដល់វគ្គបណ្ដុះបណ្ដាបច្ចេកទេសស្ដីពីការចិញ្ចឹមមាន់ស្ដីពី: ការវិភាគសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់តាមទំលាប់ និងតាមបច្ចេកទេស ចំណុចគន្លឹះសំខាន់ក្នុងការចិញ្ចឹមមាន់ទាំង៥រួមមានៈការជ្រើសរើសទីតាំង ការសាងសង់ទ្រុង ការជ្រើសរើសពូជ ការថែទាំ/ការការពារ និងព្យាបាល គោលការណ៍បច្ចេកទេស សំខាន់ៗទាំង៩ចំនុចសម្រាប់ការចិញ្ចឹម



មាន់ នៅក្នុងតំបន់ជាអាជីវកម្មកសិកម្មដែលមានផលិតភាព ដល់កសិដ្ឋានអាជីវកម្ម និងសមាជិកបានចំនួន១០វគ្គ នៅភូមិបាគូ ថ្មី បាគូ បន្ទាយគ្រោក ឃុំស្រែស្តុក ភូមិបឹងក្រាញ់ ឃុំកញ្ជរ ភូមិស្វា ឃុំស្វា ភូមិស្ទឹងក្រោម ឃុំកណ្តៀង ភូមិស្តុកជុំ ឃុំកោះជុំ ស្រុកកណ្តៀង និងភូមិអូរចង់ ទួលពង្រ ឃុំបាក់ចិញ្ចៀន ដោយមានអ្នកចូលរួមចំនួន២៤៣នាក់ ស្រី១៦៧នាក់។

- ការអនុវត្តបច្ចេកទេសស្តីពីដំណើរការនៃការប្រើប្រាស់ទូរភ្ញាស់កូនមាន់ និងការថែទាំទូរភ្ញាស់បានចំនួន១០កសិដ្ឋានដោយមានអ្នកចូលរួមចំនួន១០នាក់លើប្រធានបទសម្ខាន់ៗរួមមានៈ របៀបប្រើប្រាស់ របៀបជ្រើសរើសនិងដាក់ស៊ុតមុនពេលដាក់ចូលក្នុងទូរ ការថែរក្សាសំណើមនិងកំដៅក្នុងទូរភ្ញាស់ ការថែទាំកូនមាន់ពេលញាស់ និងរបៀបនៃការថែទាំទូរភ្ញាស់។



### ៦.គាំទ្រពូជមាន់ទៅកសិដ្ឋានចិញ្ចឹមមាន់ចំនួន១០និងចាក់ថ្នាំបង្ការៈ

ផ្តល់ការគាំទ្រមាន់ពូជជូនកសិដ្ឋានចិញ្ចឹមមាន់បានចំនួនចំនួន១០កសិដ្ឋាន នៅភូមិបឹងក្រាញ់ ឃុំកញ្ជរ ភូមិស្តុកជុំ ឃុំកោះជុំ ភូមិវាល ថ្មី បាគូ បន្ទាយគ្រោក ឃុំស្រែស្តុក ភូមិស្ទឹងក្រោម ឃុំកណ្តៀង ស្រុកកណ្តៀង ភូមិស្វាយប៉ាក ឃុំព្រងិល និងភូមិទួលពង្រ ឃុំចាក់ចិញ្ចៀន ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិសាត់ (ក្នុង១កសិដ្ឋានមេមាន់ចំនួន៤៩ក្បាល និងមាន់ឈ្មោលចំនួន៧ក្បាល) និងចាក់ថ្នាំបង្ការ មាន់សរុប៥៦០ក្បាលក្នុងនោះមាន់ឈ្មោល៧០ក្បាល។



### ៧.ការសម្របសម្រួលទីផ្សារ និងក្រុមអ្នកផលិតមាន់ៈ

EPDOបានសម្របសម្រួលជាមួយក្រុមផលិតមាន់ និងអ្នកប្រមូលទិញដែលមានសក្តានុពលក្នុងការទិញមាន់នៅស្រុកកណ្តៀង និងស្រុកភ្នំក្រវាញ បានចំនួន១០នាក់ៈ EPDOបានធ្វើការផ្សាភ្ជាប់រវាងក្រុមផលិត និងអ្នកប្រមូលទិញនៅក្នុងតំបន់ដើម្បីឲ្យក្រុមទាំងពីរបានជួបពិភាក្សាគ្នារវាងតម្រូវការទីផ្សារ និងផលិតកម្មផ្គត់ផ្គង់ទីផ្សារ ធ្វើឲ្យក្រុមផលិតមានឱកាសក្នុងការចរចារ និងការសម្រេចចិត្តក្នុងការលក់មាន់ដែលមានតម្លៃសមរម្យជាងមុន។ ក្រុមផលិតមាន់សរុបមាន២៦០នាក់ក្នុងភូមិចំនួន១០ (ភូមិបឹងក្រាញ់ ឃុំកញ្ជរ ភូមិស្តុកជុំ ឃុំកោះជុំ ភូមិវាល បាគូ បន្ទាយគ្រោក ថ្មី ឃុំស្រែស្តុក ភូមិស្វា ឃុំស្វា ភូមិស្ទឹងក្រោម ឃុំកណ្តៀង ស្រុកកណ្តៀងភូមិអូរចង់ និងទួលពង្រ ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវ៉ាញ)។

### ៨.ដំឡើងទូរភ្ញាស់កូនមាន់ចំនួន១០កន្លែងៈ

ដំឡើងទូរភ្ញាស់កូនមាន់ចំនួន១០កន្លែងក្នុងកសិដ្ឋានទាំង១០ភូមិគោលដៅ ទូរភ្ញាស់នីមួយៗត្រូវបានគ្រប់គ្រងនិងប្រើប្រាស់ដោយថាមពលអគ្គិសនី អាចប្រើបានដោយស្វ័យប្រវត្តិ។ ព្រមទាំងបច្ចេកទេសនៃការគ្រប់គ្រងទូរភ្ញាស់ និងការភ្ញាស់ពងមាន់។



**៩.ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីទស្សនៈទានអភិវឌ្ឍន៍ទីផ្សារ ៖**





វគ្គបណ្តុះបណ្តាលស្តីពីទស្សនៈទានអភិវឌ្ឍន៍ទីផ្សារ និងការផ្សារភ្ជាប់ទីផ្សារប្រតិទិនតាមរដូវកាល ដល់អ្នកដឹកនាំសហគ្រាសទាំង១០ និងកសិករគោលដៅបានចំនួន១០វគ្គ ដោយមានអ្នកចូលរួមចំនួន២៣៤នាក់ ស្រី១៨៦នាក់ ស្តីពី ការកសាងក្រុម មូលដ្ឋានគ្រឹះទីផ្សារ ការចាប់ផ្តើមអាជីវកម្ម ការគ្រប់គ្រងអាជីវកម្ម ប្រតិទិនផ្គង់ផ្គង់ទីផ្សារមាន់ សំណួរវាស់ស្ទង់សមត្ថភាពក្រោយវគ្គបណ្តុះបណ្តាល និងផែនការអនុវត្ត(មានការចូលរួមបញ្ចេញគំនិតយោបល់ពីអ្នកចូលរួម)។

**១០.ផ្តល់ការបណ្តុះបណ្តាល និងបង្កើតផែនការអាជីវកម្ម ដើម្បីឆ្លើយតបទីផ្សារៈ**





ផ្តល់ការបណ្តុះបណ្តាល និងបង្កើតផែនការអាជីវកម្មផលិតកម្មលើផែនការផលិតមាន់ ដល់អ្នកដឹកនាំសហគ្រាស និងសមាជិករបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងវិធីសាស្រ្តដឹកនាំទីផ្សារបានចំនួន១០វគ្គដោយមានអ្នកចូលរួមចំនួន២៣៩នាក់ ស្រី១៧៤នាក់ ស្តីពី ១.ការប្រៀបធៀបពីការអភិវឌ្ឍតាមបែបអាស្រ័យជំនួយ និងការធ្វើជំនួញ(ការផ្លាស់ប្តូរការគិតរបស់កសិករកុំអោយពឹងលើអាស្រ័យជំនួយ និងបណ្តុះគំនិតថ្មីអំពីរបៀបនៃការអភិវឌ្ឍន៍តាមបែបជំនួញ) ២.ការវិភាគពីសក្តានុពលនៃមុខរបរចិញ្ចឹមសត្វ និងជំរើសរបស់កសិករ ៣.របៀបធ្វើផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមសត្វ និង៤.ការរៀបចំគម្រោងផែនការមុខរបររបស់កសិដ្ឋានចិញ្ចឹមសត្វមាន់។





**១១.ដំណើរទស្សនកិច្ចសម្រាប់កសិករគម្រូ ដើម្បីបង្ហាញពីផលិតកម្មមាន់នៅក្នុងខេត្តៈ**

រៀបចំដំណើរទស្សនកិច្ចសម្រាប់ម្ចាស់កសិដ្ឋានភ្ញាស់កូនមាន់ទាំង១០និងសមាជិកបានចំនួន១លើកដោយមានអ្នកចូលរួមចំនួន១៧នាក់ ស្រី៥នាក់ ដើម្បីបង្ហាញពីផលិតកម្មមាន់នៅក្នុងភូមិធ្លក ឃុំ ស្បា ស្រុកកណ្តៀងចំនួន២កន្លែង ដំណើរទស្សនៈកិច្ចនេះ គឺចង់អោយកសិករបានរៀនសូត្រពីអ្នកចិញ្ចឹមមាន់ដែលទទួលបានជោគជ័យក្នុងការចិញ្ចឹមមាន់សាច់ និងភ្ញាស់កូនមាន់។

**១២. គាំទ្រផ្នែកបច្ចេកទេសដល់កសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្ម និងអ្នកទិញមាន់៖**

ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដល់កសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្ម និងអ្នកទិញមាន់បានចំនួន៣វគ្គ មានការចូលរួមពីក្រុមផលិតមាន់ចំនួន២០នាក់ និងឈ្មួញ/អ្នកទិញចំនួន៥នាក់ សរុប២៥នាក់ ស្រី១៤នាក់ ប្រធានបទដែលបានលើកឡើងរួមមានៈ និយមន័យអាជីវកម្មកសិកម្ម ប្រតិទិនរដូវកាល តម្រូវការទីផ្សារ តម្លៃ ប្រតិទិនផ្គង់ផ្គង់ទីផ្សារមាន់ និងទទួលបានប្រាក់ចំណេញ ការចុះកិច្ចសន្យារវាងអ្នកផលិត និងអ្នកទិញ ការវេចខ្ចប់ ការដឹកជញ្ជូន ក្នុងនេះEPDO ក៏បានសម្របសម្រួលឱ្យអ្នកទិញមាន់ពិភាក្សាជាមួយក្រុមផលិតមាន់ពីតម្រូវការទីផ្សារមាន់ ទម្ងន់មាន់ ពណ៌សម្បុរ រដូវកាល ដែលទីផ្សារពេញនិយម ដើម្បីងាយស្រួលក្នុងការផលិតផ្គត់ផ្គង់ទីផ្សារ។

**១៣.រៀបចំកិច្ចប្រជុំក្រុមអ្នក ផលិតមាន់ និងឈ្មួញ/អ្នកទិញតាមរយៈវេទិកាពហុអ្នកពាក់ព័ន្ធៈ**



សម្របសម្រួលវេទិកាពិគ្រោះយោបល់រវាងកសិករក្រុមផលិតមាន់ និងឈ្មួញ/អ្នកទិញមាន់ ចំនួន៣វគ្គ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីលោកប្រធានកសិកម្មស្រុក លោកមេឃុំ លោកមេភូមិ និងកសិករក្រុមផលិតមាន់ ឈ្មួញទិញមាន់ សរុបចំនួន៧៣នាក់/ស្រី៤៥នាក់ (ឃុំស្រែស្តុក មួយលើក មានអ្នកចូលរួម៣០នាក់ ស្រី១៤នាក់ ឃុំ ស្យា មួយលើកមានអ្នកចូលរួម ២៣នាក់ ស្រី ១៣នាក់ និង ឃុំបាក់ចិញ្ចៀនមួយលើក ២០នាក់/ ស្រី១៨នាក់) វេទិកានេះក្នុងគោលបំណងពង្រឹងភាពអង់អាចរបស់កសិករខ្នាតតូច ជាពិសេសស្ត្រី ដើម្បីពិភាក្សា និងបង្កើតនូវសម្លេងរួមគ្នា រវាងអ្នកផលិត អ្នកទិញក្នុងការលើកបញ្ហាដែលគូរភាគីទាំងនោះជួបកន្លងមក និងរកដំណោះស្រាយរួមគ្នាដើម្បីទទួលបានផលប្រយោជន៍ទាំងសងខាងសម្រាប់ឈានទៅរកការចុះកិច្ចសន្យា។

**១៤.រៀបចំទិវាផ្សព្វផ្សាយផលិតកម្មមាន់និងលក់មាន់ទៅឱ្យកសិដ្ឋានផ្សេងៗដែលមានចំណាប់អារម្មណ៍**



សម្របសម្រួលទិវាផ្សព្វផ្សាយផលិតកម្មមាន់ និងលក់មាន់ទៅឱ្យកសិដ្ឋានផ្សេងៗដែលមានចំណាប់អារម្មណ៍ ឬសមាជិក បានចំនួន៣វគ្គនៅភូមិអូររំចង់ ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវ៉ាញ និងភូមិថ្មីភូមិ វាល ឃុំ ស្រែស្តុក ស្រុកកណ្តៀង ដោយមានការចូលរួមពីអជ្ញាធរភូមិ កសិករក្រៅក្រុម និងសមាជិកក្រុមសរុបចំនួន១៤៤នាក់ ស្រី ៩៣នាក់។

**១៥.រៀបចំទិវាប្រគល់កូនមាន់របស់កសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្មទាំង១០ ដល់សមាជិកក្រុម៖**





សម្របសម្រួលទិវាប្រគល់កូនមាន់ដែលមានអាយុ៣សប្តាហ៍ចំនួន ៣៧៥០ក្បាល របស់កសិដ្ឋានគម្រូ ជូនកសិករជាសមាជិកក្រុមចំនួន២៥០ គ្រួសារ ដោយ១គ្រួសារទទួលបាន១៥ក្បាល ក្នុងតំបន់គោលដៅទាំង១០ភូមិ គ្រួសារទាំងនេះមុននឹងទទួលបានកូនមាន់យកទៅចិញ្ចឹម ពួកគាត់បានចូលរួមវគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ ព្រមទាំងមានការណែនាំពីអ្នកជំនាញពីរបៀបថែទាំកូមាន់ដែលនៅតូចៗ គ្រប់គ្រងសីតុណ្ហភាពសម្រាប់កូនមាន់ ការផលិតចំណី និងឲ្យចំណីកូនមាន់បន្ថែម ដើម្បីឲ្យពួកគាត់ចិញ្ចឹមទទួលបានជោគជ័យ។

**១៦.រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង ដើម្បីទទួលបានមតិឬការផ្តល់យោបល់ពីអ្នកពាក់ព័ន្ធសំខាន់ៗ ៖**



សិក្ខាសាលាឆ្លុះបញ្ចាំងពីលទ្ធផលនៃការអនុវត្តសកម្មភាពគម្រោង ដើម្បីទទួលបានមតិយោបល់ឬការផ្តល់យោបល់ពីអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងមេដឹកនាំ និងសមាជិកកសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្ម នៅសាលប្រជុំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ ដោយមានអ្នកចូលរួមចំនួន៥១នាក់ ស្រី១៤នាក់។ ក្នុងសិក្ខាសាលានេះ ក៏បានរៀបចំអោយមានក្រុមពិភាក្សាគ្នាពីសំណួរ ក្រោយពេលបញ្ចប់គម្រោង "ខ្សែច្រវ៉ាក់ផលិតកម្មមាន់" តើកសិកម្មស្រុក ឃុំ ភូមិ និងកសិដ្ឋាននិមួយៗ ធ្វើសកម្មភាពអ្វីខ្លះដើម្បីរៀបចំផែនការ ជួយដល់ក្រុមទាំងនេះ ។

### .១៧. កិច្ចសហការ និងបណ្តាញការងារ

នៅពេលចាប់ផ្តើមអនុវត្តគម្រោងនេះ EPDO បានជួបពិភាក្សាជាមួយមន្ត្រីផ្នែកផលិតកម្ម និងបសុព្យាបាលស្រុកកណ្តៀង និងក្រុងពោធិ៍សាត់ ដើម្បីធ្វើការទំនាក់ទំនង និងសុំកិច្ចសហការណ៍ពីការអនុវត្តគម្រោងខ្សែច្រវ៉ាក់ផលិតកម្មមាន់ ក្នុងការជួបគ្នានេះEPDOបានបង្ហាញពីគោលបំណងគម្រោង សកម្មភាព វិធីសាស្ត្រនៃការអនុវត្តគម្រោង និងការគាំទ្ររបស់គម្រោង ចំណែកមន្ត្រីផលិតកម្ម និងបសុព្យាបាលវិញបានណែនាំពីតំបន់គោលដៅដែលបានកំពុងអនុវត្តគម្រោង ASPIRE ដល់ EPDO ផងដែរ និងបានបង្ហាញពីឃុំ ភូមិអោយEPDO ធ្វើការជ្រើសរើស និងសិក្សាបន្ថែមសម្រាប់ការអនុវត្តគម្រោង ហើយបន្ទាប់ពីធ្វើការជ្រើសរើសបានហើយសូមជូនដំណឹងត្រឡប់វិញផង។

ជួបពិភាក្សាជាមួយឃុំ និងភូមិដើម្បីធ្វើការទំនាក់ទំនង សុំកិច្ចសហការណ៍ពីការអនុវត្តគម្រោងខ្សែច្រវ៉ាក់ផលិតកម្មមាន់ ក្នុងការជួបគ្នានេះEPDOបានបង្ហាញពីគោលបំណងគម្រោង សកម្មភាព វិធីសាស្ត្រនៃការអនុវត្តគម្រោង និងការគាំទ្ររបស់គម្រោង ចំណែកឃុំបានចង្អុលបង្ហាញពីភូមិដែលបានកំពុងអនុវត្តគម្រោង ASPIRE ជូន EPDO ផងដែរ និងបានប្រាប់ពីភូមិអោយEPDO ធ្វើការជ្រើសរើស និងសិក្សាសម្រាប់ការអនុវត្តគម្រោង ដើម្បីកុំឲ្យជាន់គ្នាជាមួយគោលដៅដែលកម្មវិធីASPIRE បាន និងកំពង់អនុវត្តកន្លងមក។

ទំនាក់ទំនងជាមួយក្រុមហ៊ុន មេឌីវែត ដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់បុគ្គលិកចំនួន២នាក់ និងកសិករចំនួន៥នាក់ ពីបច្ចេកទេស និងការគ្រប់គ្រងមាន់ស្រែចំនួន១ថ្ងៃ នៅភូមិកំពង់សំបួរ ឃុំស្វា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ព្រមទាំងបាននាំអ្នកជំនាញអោយទៅពិនិត្យមើល និងវិនិច្ឆ័យជម្ងឺមាន់នៅភូមិស្វា ឃុំស្វា បន្ទាប់ពីពិនិត្យ និងវះកាត់មានឈឺរួចមកឃើញថាមាន់របស់គាត់បានកើតជម្ងឺញូវកាសហើយ អ្នកជំនាញទាំងនោះបានធ្វើការណែនាំដល់កសិករដើម្បីទិញថ្នាំវ៉ាកសាំងការពារដល់មាន់ដែលមិនទាន់បានកើតជម្ងឺ។

## ១.៤. លទ្ធផលចុងក្រោយកម្មវិធី:

### ១.លទ្ធផល រយៈពេលខ្លី:

1. ការចញ្ចឹមមាន់ដោយប្រើប្រាស់វ៉ាក់សាំងការពារជម្ងឺ ធ្វើអោយកាត់បន្ថយបាននូវជម្ងឺផ្សេងៗ ព្រមទាំងមានភាពធន់នឹងអាកាសធាតុក្តៅខ្លាំង។
2. កសិករដែលទទួលមានការបណ្តុះបណ្តាលបច្ចេកទេស បានយកចំណេះដឹងទៅអនុវត្តន៍ ជាពិសេសគឺម្ចាស់កសិដ្ឋានភ្ញាស់កូនមាន់។
3. ម្ចាស់កសិដ្ឋានទទួលបានមេមាន់ពូជ និងមាន់បា និងទូរភ្ញាស់កូនមាន់ សម្រាប់ពង្រីកមុខរបរអាជីវកម្មមាន់។
4. សមាជិកក្រុមចំនួន២៥០គ្រួសារទទួលបានកូនមាន់ពូជទៅចិញ្ចឹម សម្រាប់ពង្រីកមុខរបរចិញ្ចឹមមាន់បន្ថែម។
5. កសិដ្ឋានចិញ្ចឹមមាន់និមួយមានសមត្ថភាពក្នុងការប្រើប្រាស់ និងគ្រប់គ្រងទូរភ្ញាស់បានល្អដូចជាៈ កំដៅ សំណើម ចរន្តខ្យល់ អត្រាញាស់ និងអនាម័យ។

### ២. លទ្ធផលរយៈពេលមធ្យមៈ

- ចិញ្ចឹមមាន់តាមបច្ចេកទេសមានធ្វើជាទ្រុងខណ្ឌដាច់ពីគ្នា រវាងមេមាន់យកពង មាន់សាច់ និងកូនមាន់។
- មានកូនមាន់សម្រាប់ចែកជូនសមាជិកក្រុមចំនួន២៥នាក់ ដោយម្នាក់ៗទទួលបានកូនមាន់១៥ក្បាល មានអាយុ៣សប្តាហ៍ និងធ្វើវ៉ាក់សាំងរួប។
- ទទួលបានប្រាក់ចំណូលប្រសើរជាងមុនពីការលក់មាន់សាច់ និងកូនមាន់
- ជាកន្លែងប្រឹក្សាយោបល់ ចែករំលែកបទពិសោធន៍ បច្ចេកទេសដល់សមាជិកក្រុមក្នុងភូមិ និងក្រៅភូមិ
- ជាទីតាំងផលិត និងផ្គត់ផ្គង់ពូជ ស៊ុត មាន់សាច់ និងកូនមាន់។
- ភាពជោគជ័យការចិញ្ចឹមមាន់ធ្វើអោយសមាជិកក្រុមមានការជឿជាក់លើកសិដ្ឋានកម្រូ
- ការភ្ញាស់កូនមាន់ដោយប្រើទូរស្វ័យប្រវត្តិធ្វើអោយមានភាពងាយស្រួលក្នុងការគ្រប់គ្រង ថែទាំ អនាម័យ មានអត្រាញាស់បានច្រើនពី៧៥%៨៥ទៅ% មេអាចពងបានពី៦ ទៅ ៧ដងក្នុង១ឆ្នាំ។

តាមសំដីរបស់គ្រួសារលោក ប៊ិត គា នៅភូមិវាល ឃុំស្រែស្ពុក ក្រុកកណ្តៀង ជាម្ចាស់កសិដ្ឋានចិញ្ចឹមមាន់បានរៀបរាប់ប្រាប់អោយដឹងថាបន្ទាប់ពីមានការគាំទ្រពីគម្រោង គ្រួសារគាត់ទទួលបានជោគជ័យក្នុងការចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ បច្ចុប្បន្នគាត់មានមាន់មេ៨០ក្បាល ឈ្មោល៨ មាន់សាច់២០ក្បាល និងកូនមាន់២០០ក្បាល ហើយបានផ្តល់កូនមាន់ដល់សមាជិកក្រុមបានចំនួន៣៧៥ក្បាល នៅសល់កូនមាន់២០០ក្បាលសម្រាប់លក់ និងចិញ្ចឹមយកសាច់ ក្រៅពីចំណូលការលក់កូនមាន់ គាត់ទទួលបានពីការកល់មាន់សាច់ក្នុងរយៈពេល៤ខែបាន១.១២០.០០០រ ចំណូលទាំងនេះគ្រួសារគាត់យកទៅពង្រីកទ្រុងមាន់សាច់ ទ្រុងដាក់កូនមាន់ ចំណីនិងវ៉ាក់សាំងមាន់ និងចំណាយក្នុងគ្រួសារ។

តាមរយៈវេទិការពិគ្រោះយោបល់រវាងក្រុមផលិតមាន់ និងឈ្មួញទិញមាន់ បានធ្វើអោយក្រុមបណ្តុំអាជីវកម្មទាំងនេះមានការផ្លាស់ប្តូរដូចជាៈ សមាជិកក្រុមលក់រួមគ្នា មានសាមគ្គីភាពក្នុងក្រុម ទទួលបានអត្ថប្រយោជន៍ពីសេវាទីផ្សារ និងតម្លៃសមរម្យជាជាងការលក់រាយតាមគ្រួសារ ហើយបង្កលក្ខណៈងាយស្រួលដល់ក្រុមផលិតក្នុងការលក់មាន់ និងអ្នកទិញមាន់ដូចជាៈ

- មានលេខទូរសព្ទ័ទំនាក់ទំនងក្នុងការជ្រើសរើសឈ្មួញប្រមូលទិញលក់/
- សមាជិកក្រុមមិនពិបាកដឹកមាន់យកមកលក់នៅផ្សារ ព្រមទាំងមានជម្រើសក្នុងការសម្រេចចិត្តលក់
- ឈ្មួញមិនពិបាកដើរប្រមូលទិញមាន់តាមផ្ទះ
- សមានជិកក្រុមរបស់គាត់បានជួបពិភាក្សាជាមួយឈ្មួញ និងផលិតមាន់តាមតម្រូវការរបស់ឈ្មួញ
- លក់មាន់រួមគ្នា មានតម្លៃសមរម្យ។

### ៣. កត្តាប្រឈម និងបញ្ហាជួបប្រទះ

- ដាច់ភ្លើងញឹកញាប់ធ្វើឲ្យស៊ុតមិនអាចញាស់បាន
- អាកាសធាតុក្តៅខ្លាំង ធ្វើឲ្យមាន់មានជម្ងឺផ្លូវដង្ហើម

ដំណោះស្រាយ

- ពេលខ្លះយកពងមាន់ដែលមិនទាន់ញាស់ឲ្យមេមាន់ក្រាបជំនួសវិញ ម្តងម្កាលពេលដាច់ភ្លើង
- ដើម្បីកាត់បន្ថយកំដៅខ្លាំងEPDO បានណែនាំកសិករអោយយកស្លឹកដូងគ្របពីលើដំបូល និងបាញ់ទឹកលើដំបូល និងក្នុងទ្រុងអោយបានញឹកញាប់ ដាំដើមឈើពហុប្រយោជន៍ជុំវិញទ្រុង។

### ៤. មេរៀន រៀនសូត្រទទួលបាន៖

១.បន្ទាប់ពីផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ចប់ បានដឹកនាំកសិករទៅទស្សនៈកិច្ចសិក្សាលើការអនុវត្តផ្ទាល់ពីការចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ ធ្វើអោយពួកគាត់មានការយល់កាន់តែច្បាស់បានលឿន ព្រមទាំងមានផែនការផលិតសម្រាប់ម្នាក់ៗក្នុងការចិញ្ចឹមមាន់។

២.ការចិញ្ចឹមមាន់ដាក់ទ្រុងមាន ទ្រុងដេក និងទ្រុងដើរ ធ្វើអោយមាន់កាត់បន្ថយបាននៅជម្ងឺផ្សេងៗ ងាយស្រួលក្នុងការគ្រប់គ្រង ថែទាំ និងការផ្តល់ចំណីអោយបានគ្រប់គ្រាន់។

៣.ការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន ការធ្វើវ៉ាក់សាំងមាន់បែបគីមីតែមួយមុខមិនសូវមានប្រសិទ្ធិភាពទេ កសិករមួយចំនួនបានធ្វើវ៉ាក់សាំងធម្មជាតិខ្លួនឯង បូកផ្សំជាមួយវ៉ាក់សាំងគីមី ធ្វើអោយមាន់របស់គាត់មានភាពធន់និងជម្ងឺ និងមានសុខភាពល្អ។

៤.ការផ្សំចំណីធម្មជាតិជាមួយ និងចំណីទីផ្សារ ធ្វើអោយមាន់មានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ធាត់ធំលឿន និងមានសុខភាពល្អ ឆាប់បានលក់ ព្រមទាំងចំណាយដើមទុនតិច។

៥.ការភ្ញាស់កូនមាន់ដោយប្រើទូរស្វ័យប្រវត្តិធ្វើអោយមានភាពងាយស្រួលក្នុងការគ្រប់គ្រង ថែទាំ អនាម័យមានអត្រាញាស់បានច្រើនពី៧៥%ទៅ៨៥% មេអាចពងបានពី៦ ទៅ ៧ដងក្នុង១ឆ្នាំ។

### ៥. អនុសាសន៍៖

១.ដើម្បីអោយការចិញ្ចឹមមាន់ទទួលបានជោគជ័យល្អ កសិករទៅតាមបច្ចេកទេសអោយបានត្រឹមត្រូវដោយផ្តោតសំខាន់ទៅលើ:

- ទីតាំងទ្រុង: អនុវត្តទៅតាមបច្ចេកទេសនៃការសាសង់ទ្រុងសមស្របទៅនឹងបរិមាណមាន់
- ទ្រុង: ការបែងចែកទ្រុងមេ/បា ទ្រុងបំបែកកូន និងទ្រុងមានសាច់ផ្សេងៗពីគ្នា ជាចំណុចសំខាន់
- ពូជ: ជ្រើសរើសពូជមានសុខភាពល្អ និងវ៉ាក់សាំងការពារ
- ការថែទាំ: ធ្វើអនាម័យស្នូកទឹក/ចំណីអោយបានត្រឹមត្រូវក្នុងទ្រុងចិញ្ចឹមគ្រប់ពេល និងធ្វើវ៉ាក់សាំងធម្មជាតិ និងគីមី ចំណី: ផ្សំចំណីធម្មជាតិ និងចំណីគីមី ព្រមទាំងផ្សំតាមរូបមន្តត្រឹមត្រូវ ធ្វើអោយមាន់លូតលាស់លឿន និងធនជម្ងឺ។

២.ដើម្បីកាត់បន្ថយជម្ងឺមាន់ កសិដ្ឋានចិញ្ចឹមមាន់និមួយៗត្រូវជ្រើសរើសទីតាំងលក់វ៉ាក់សាំងដែលមានគុណភាព ប្រើបូករួមជាមួយវ៉ាកសាំងធម្មជាតិសម្រាប់កូនមាន់ ធ្វើវ៉ាក់សាំងអោយបានគ្រប់ចំនួន និងទៀងទាត់។

៣.ដើម្បីចិញ្ចឹមមាន់អោយបានធំ ធាត់ល្អ សមាជិកចិញ្ចឹមមាន់ទាំងអស់ត្រូវរៀបចំទ្រុងតាមលក្ខណៈបច្ចេកទេសមានទ្រុងខណ្ឌជាចពីគ្នារវាងមាន់ពង មាន់យកសាច់ កូនមាន់ កុំលែងក្រៅទ្រុង ក្នុងទ្រុងនិមួយៗត្រូវមានរណ្តៅដីកំប៉ុស្ត

សំរាប់មាន់កាយ មានដាំដើមឈើពហុប្រយោជន៍ជំវិញទ្រុង ដើម្បីការពារកំដៅ និងជាចំណីមាន់ នៅមាត់ទ្វារចូលទ្រុង ត្រូវមានកំបោជាន់ការពារចំឡងរោគ។

៤.សម្រាប់កសិករដែលមានទូរភ្ញាស់កូនមាន់ ត្រូវច្បាស់ពីបច្ចេកទេសប្រើប្រាស់ទូរភ្ញាស់ (សំណើម កំដៅ និងចរន្តខ្យល់ចេញចូល ការប្តូរទីតាំងកញ្ច្រែងដាក់ពងមាន់) តាមដានធាតុអាកាសខាងក្រៅជាប្រចាំដើម្បីកំណត់សីតុណ្ហភាពខាងក្នុងទូរ ត្រួតពិនិត្យទឹកក្នុងទូរភ្ញាស់ត្រប្តូររយៈពេល២៤ម៉ោងម្តង។

## ៦. សន្និដ្ឋាន

គម្រោងនេះបានជួយដល់កសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្មចំនួន១០កសិដ្ឋាន ដែលមានអ្នកទទួលផលសរុបចំនួន២៦០គ្រួសារ។ រៀបចំរចនាសម្ព័ន្ធក្រុម និងអ្នកដឹកនាំអាជីវកម្មផលិតមាន់ជាមួយក្រុមអ្នកផលិត និងកំណត់ជាសហគ្រាសបានចំនួន១០ក្រុម មានគោលការណ៍ លក្ខន្តិកៈក្រុម បានបណ្តុះបណ្តាបច្ចេកទេសស្តីពីការចិញ្ចឹមមាន់ក្នុងតំបន់ជាអាជីវកម្មកសិកម្មដែលមានផលិតភាពដល់កសិដ្ឋាន និងសមាជិកបានចំនួន១០វគ្គ រួមមាន៖

បច្ចេកទេសស្តីពីការប្រើប្រាស់ទូរភ្ញាស់កូនមាន់ និងការថែទាំទូរភ្ញាស់បានចំនួន១០កសិដ្ឋាន។ បច្ចេកទេសដល់កសិដ្ឋានចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្ម និងការបង្កើតផែនការអាជីវកម្មផលិតកម្មមាន់ បានចំនួន២វគ្គ ទស្សនៈទានអភិវឌ្ឍន៍ទីផ្សារ និងការផ្សាភ្ជាប់ទីផ្សារ ដល់អ្នកដឹកនាំសហគ្រាសទាំង១០ និងកសិករគោលដៅបានចំនួន១០វគ្គ។ គាំទ្រមាន់ពូជជូនកសិដ្ឋានចិញ្ចឹមមាន់បានចំនួន១០កសិដ្ឋាន ដែលមានមាន់សរុប៥៦០ក្បាល ១កសិដ្ឋានទទួលបានមេមាន់ចំនួន៤៩ក្បាល និងមាន់ឈ្មោលចំនួន៧ក្បាល និងចាក់ថ្នាំបង្ការរួចរាល់។ គាំទ្រទូរភ្ញាស់កូនមាន់ចំនួន១០កន្លែងក្នុងកសិដ្ឋានទាំង១០ភូមិ ។ រៀបចំទិវាផ្សព្វផ្សាយផលិតកម្មមាន់ និងទីផ្សារដល់កសិដ្ឋានផ្សេងៗដែលមានចំណាប់អារម្មណ៍ ឬសមាជិកបានចំនួន៣វគ្គ គាំទ្រកូនមាន់ដែលមានអាយុ៣សប្តាហ៍ចំនួន៣៧៥០ក្បាល ជូនកសិករជាសមាជិកក្រុមចំនួន២៥០គ្រួសារ ក្នុងតំបន់គោលដៅទាំង១០ភូមិ។ ជាទូទៅ EPDO បានដំណើការគម្រោងស្របទៅតាមផែនការដែលបានគ្រោងទុក និងសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

# ២. គម្រោងជំរុញផលិតកម្មស្បៀង

## BOOSTING FOOD PRODUCTION PROGRAM ( BFP )

## ឧបត្ថម្ភដោយ៖ រាជរដ្ឋាភិបាលកម្ពុជា

**១ សេចក្ដីផ្ដើម:**

សារបានគម្រោងជំរុញផលិតកម្មស្បៀង គឺកើតចេញពីការផ្ដួចផ្ដើមរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានរកឃើញនៅឆ្នាំ២០១៥ ប្រទេសកម្ពុជាបាននាំបន្លែចូលយ៉ាងច្រើនពីប្រទេសជិតខាងដែលមានទឹកប្រាក់ប្រមាណជាង២០០លានដុល្លារក្នុងមួយឆ្នាំ ហើយតម្លៃអាហារប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានតម្លៃថ្លៃ មិនអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបានទេ។ ក្នុងកិច្ចអន្តរាគមន៍កន្លងមករាជរដ្ឋាភិកម្ពុជា និងដៃគូរអភិវឌ្ឍន៍ ភាគច្រើនបានផ្ដោតទៅលើតែកសិករខ្នាតតូច និងខ្វះភាពប្រទាក់ក្រឡាគ្នាក្នុងខ្សែច្រវាក់ផលិតកម្ម កសិកម្ម រួមទាំងទីផ្សារផលិតផលកសិកម្ម។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើកម្មសិក្សាមួយស្ដីកម្មវិធីជំរុញផលិតកម្មស្បៀង និងបានលើកគម្រោងអនុវត្តក្នុងដំណាក់កាលទីមួយទទួលបានលទ្ធផលគួរជាទីមោទនៈ ក្នុងនេះគិតត្រឹមខែធ្នូឆ្នាំ២០១៩នេះ គម្រោងជុំរុញផលិតកម្មស្បៀង បានជំរុញផលិតកម្មបន្លែសុវត្ថិភាពអោយមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំទាំងបរិមាណ និងគុណភាពនូវបន្លែមានសុវត្ថិភាពសម្រាប់លក់នៅទីផ្សារក្នុងស្រុក ដែលមានការទទួលស្គាល់គុណបន្លែក្នុងស្រុកពីសំណាក់អ្នកប្រើប្រាស់ និងបានផ្គត់ផ្គង់ទៅទៅអោយហាងលក់បន្លែសុវត្ថិភាពមួយចំនួន។

ទោះជាយ៉ាងនេះក្ដី គម្រោងកម្មវិធីជម្រុញផលិតកម្មស្បៀងដំណាក់ការទី១ បានផ្ដល់ប្រយោជន៍ដល់អ្នកទទួលផលដោយផ្ទាល់ចំនួន១៧០គ្រួសារ មានមនុស្សសរុប៦៨០នាក់ និងអ្នកទទួលផលដោយប្រយោលបមាណ ៨៥០គ្រួសារ មានមនុស្សសរុប៣៤០០នាក់ ក្នុងភូមិគោលដៅចំនួន១៩ភូមិ ៨ឃុំ ក្នុងស្រុកចំនួន៣នៃខេត្តពោធិ៍សាត់ ជាតំបន់ដែលមានសក្តានុពលក្នុងការដាំបន្លែ។ គម្រោងនេះមានរយៈពេល១២ខែចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ទទួលបានការគាំទ្រថវិកាពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**១.ឈ្មោះគម្រោង:** គម្រោងជំរុញផលិតកម្មស្បៀង (BOOSTING FOOD PRODUCTION PROGRAM (BFP)

**២.ប្រភពជំនួយ:** អគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**៣.គោលដៅ:** បង្កើនផលិតកម្មបន្លែ ដែលមានការប្រកួតប្រជែង និងមានសុវត្ថិភាពជាងមុន។

**៤.លទ្ធផលរយៈពេលវែង:** ការផលិតបន្លែដើម្បីជំនួសបន្លែនាំចូល និងឆ្លើយតបទៅនឹងតម្រូវការអ្នកបរិភោគអោយកាន់តែប្រសើរជាងមុន ដោយធ្វើអោយបន្លែមានតម្លៃថោកជាងមុន និងមានគុណភាពល្អជាងមុន។

**៥.គោលបំណង:** សម្រេចអោយបាននៅការចូលរួមក្នុងការប្រកួតប្រជែងប្រកបដោយនិរន្តរភាព នៃការផលិតមុខបន្លែមួយចំនួន ដែលជំនួសការនាំចូលដែលចេះតែកើនឡើងជាលំដាប់ អោយបាន៦០០០០តោនក្នុងឆ្នាំនេះ។

**៦.តំបន់គោលដៅ:** ភូមិគោលដៅចំនួន១៩ភូមិ ៨ឃុំ ក្នុងស្រុកបាកាន ភ្នំក្រវ៉ាញ និងក្រុងពោធិ៍សាត់ ជាតំបន់ដែលមានសក្តានុពលក្នុងការដាំបន្លែ។

**៧.អ្នកទទួលផល:** កសិករផលិតបន្លែខ្នាតមធ្យមចំនួន១៦៧គ្រួសារ និងខ្នាតធំចំនួន៣គ្រួសារ។ ដោយជ្រើសរើស និងផ្តល់ការគាំទ្រជាចំបងដល់កសិករដែលមានសក្តានុពលក្នុងការដាំបន្លែតែប៉ុណ្ណោះ។

**៨.រយៈពេលអនុវត្តគម្រោង:** ចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

**៩.ថវិកា: ១៤៨.០៦៨.០០០៛**

## ២. លទ្ធផលសម្រេចបាន:

**១.ផលិតកម្មបន្លែរបស់កសិករគោលដៅក្នុងគម្រោង:** EPDO បានជ្រើសរើស និងសហការគាំទ្រាំដល់កសិករផលិតបន្លែជាអាជិពចំនួន១៧០គ្រួសារ ក្នុងភូមិគោលដៅចំនួន១៩ភូមិ ៨ឃុំ ក្នុងស្រុកបាកាន ភ្នំក្រវ៉ាញ និងក្រុងពោធិ៍សាត់។ កសិករទាំងនោះត្រូវបានរៀបចំជាក្រុមផលិតបន្លែសុវត្ថិភាព ចំនួន១១ក្រុម (ក្រុមនិមួយៗមានកសិករពី៩ ទៅ ២៧នាក់) ដើម្បីផលិតបន្លែសុវត្ថិភាពតាមគោលការណ៍ការអនុវត្តកសិកម្មល្អ(GAP) ហើយក្រុមផលិតដែលមានសក្តានុពលត្រូវបានបង្កើតជាសហគមន៍កសិកម្មផលិតបន្លែ។

**២.បង្កើតក្រុមកសិករ និងសហគមន៍កសិកម្មផលិតបន្លែ:**

EPDO បានរៀបចំក្រុមបានចំនួន១១ក្រុម មានសមាជិកសរុបចំនួន១៧០នាក់ ក្នុងភូមិគោលដៅចំនួន១៩ភូមិ ៨ឃុំ ក្នុងស្រុកបាកាន ភ្នំក្រវ៉ាញ និងក្រុងពោធិ៍សាត់ និងកសិករខ្នាតធំចំនួន៣គ្រួសារ។ ការបង្កើតអោយមានជាក្រុមនេះ គឺដើម្បីងាយស្រួលក្នុងការទំនាក់ទនងគ្នា គ្រប់គ្រង ដឹកនាំ រៀបចំប្រតិទិន្នដាំដុះអោយបានច្បាស់លាស់ តាមតម្រូវការទីផ្សារ និងធានាការផ្គត់ផ្គង់អោយបានជាប្រចាំតាមបរិមាណតម្រូវការ និងទទួលបានតម្លៃសមរម្យ។ គម្រោងនេះ EPDO បានជ្រើសរើសយកតែកសិករដែលមានការដាំបន្លែជាអាជីព មានការស្មគ្រ័ចិត្តក្នុងការដាំបន្លែសុវត្ថិភាពសម្រាប់ផ្គត់ផ្គងទៅនិងទីផ្សារ។ បច្ចុប្បន្នក្រុមកសិករទាំងនេះបានចងក្រងជាសហគមន៍កសិកម្មចំនួន៣ ក្រោមការគាំទ្រដោយគម្រោងជំរុញផលិតកម្មស្បៀង។

| ល.រ | ឈ្មោះសហគមន៍កសិកម្មដែលបានបង្កើត | ចំនួនកសិករ | ស្រុក | ផ្ទៃដី (ហត) | ថ្ងៃខែឆ្នាំបង្កើត |
|---|---|---|---|---|---|
| 1 | ដប់បាតអភិវឌ្ឍន៍ | ៤៦ | ក្រុងពោធិ៍សាត់ | ២៣.៣៧ | ២៣/០៥/១៩ |
| 2 | អូរច្រូវរីកចម្រើន | ៤០ | ក្រុងពោធិ៍សាត់ | ២១.១៥ | ២៤/០៥/១៩ |
| 3 | ផ្សារអណ្តែតចម្រើនផល | ៣០ | បាកាន | ១២,៣៩ | ២២/០៥/១៩ |
| | **សរុប** | ១២៦ | | ៤៥.៦៩ | |

**៣.ការបណ្តុះបណ្តាលបច្ចេកទេស ទស្សនៈកិច្ចសិក្សា និងការធ្វើចំការបង្ហាញបន្លែសុវត្ថិភាព:**

EPDO បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសការអនុវត្តកសិកម្មល្អបានចំនួន៣៦វគ្គ ដោយមានអ្នកចូលរួមចំនួន១៧០នាក់ ដល់កសិករគោលដៅទាំង៥ក្រុម និង៣សហគមន៍កសិកម្ម។ ដែលមានប្រធានបទដូចខាងក្រោម:

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល និងធ្វើបង្ហាញ | ចំនួនវគ្គ | ចំនួនអ្នកចូលរួម | % អ្នកបានអនុវត្តបច្ចេកទេស |
|---|---|---|---|---|
| 1 | ការគ្រប់គ្រងសហគមន៍កសិកម្ម | ៣ | ២៤/៨ស | ២៤ |

| | | | | |
|---|---|---|---|---|
| 2 | ការចុះបញ្ជីគណនេយ្យសម្រាប់សហគមន៍កសិកម្ម | ៣ | ២៤/៨ស | ២៤ |
| 3 | ការធ្វើជីកំប៉ុស្តគោក ជីកំប៉ុស្តទឹក និងការធ្វើថ្នាំពុលធម្មជាតិ: | ១១ | ១៧០ | ៨៥ |
| 4 | បច្ចេកទេសក្រោយពេលប្រមូលផល | ១១ | ១៧០ | ១៧០ |
| 5 | ការណែនាំអំពីការរៀបចំផែនការផលិត ស្រមតាមតម្រូវការទីផ្សារ | ១១ | ១៧០ | ១៥៨ |
| | **សរុប** | ៣៩ | ១៧០ | ១៧០ |

### ៤.ការងារផ្នែកផ្សារភ្ជាប់ទីផ្សារផ្នែកដំណាំបន្លែ:

ដើម្បីជួយសម្របសម្រួលទីផ្សារដល់កសិករ មន្ត្រីរបស់EPDOបានចុះអង្កេតបរិមាណតម្រូវការបន្លែនិងតម្លៃបន្លែរៀងរៀលខែ ដើម្បីផ្តល់ពត៌មានដល់កសិករ ព្រមទាំងសម្របសំរួលអោយមានជំនួបគ្នារវាងអ្នកទិញ និងកសិករបានចំនួន៨លើក ដោយមានអ្នកចូលរួមចំនួន៣៧នាក់ ស្រី២៣នាក់ ក្នុងឈ្មួញឈ្មួទិញបន្លែ១៧នាក់ ស្រី១២នាក់ នៅភូមិអូរថ្កូវ ដប់បាត វាល អូរព្រាល បឹងឈូក ប្រឡាយរំដេង និងផ្សារអណ្តែត។

### ៥.កំណត់អត្តសញ្ញាណអ្នកប្រមូលទិញបន្លែ:

EPDOបានកំណត់ឈ្មួញទិញបន្លែចំនួន១៧នាក់ ដែលមានសក្តានុពលក្នុងការប្រមូលទិញបន្លែក្រុងពោធិ៍សាត់ចំនួន៧នាក់ ស្រុកបាកានចំនួន៣នាក់ និងស្រុកភ្នំក្រវ៉ាញចំនួន៧នាក់ ពួកគាត់បានចូលទៅទិញបន្លែជារៀងរាល់ថ្ងៃ សម្រាប់ផ្គត់ផ្គង់នៅផ្សារពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង និងភ្នំពេញ។

### ៦.ការសម្របសម្រួលចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់បន្លែសុវត្ថិភាពរវាងក្រុមហ៊ុន និងអ្នកផលិតផលិតៈ

សម្របសម្រួលអោយមានការជួបគ្នារវាងក្រុមផលិត និងក្រុមហ៊ុនមាសបៃតងដោយមានអ្នកចូលរួមចំនួន១៤នាក់ ស្រី១០នាក់ ការជួបគ្នានេះក្នុងគោលបំណងដើម្បីចុះកិច្ចសន្យាលក់ និងទិញបន្លែសុវត្ថិភាពនៅភូមិដប់បាត សង្កាត់លលកសរ ក្រុងពោធិ៍សាត់ ដើម្បីបញ្ជាក់ពីតម្លាភាព គូភាគីនិមួយៗបានបង្ហាញពីចំណុចសម្ខាន់ៗដូចជា:

សហគន៍: បានរៀបរាប់ពីប្រភេទបន្លែដែលសហគមន៍មាន បង្ហាញពីបច្ចេកទេសដាំបន្លែសុវត្ថិភាព បង្ហាញពីប៉ាន់បន្លែដែលមាន ជ្រើសរើសប្រភេទបន្លែដែលត្រូវចុះកិច្ចសន្យា បញ្ជាក់ពីតម្លៃបន្លែដែលលក់បាន យោងទៅតាមស្ថានភាព និងពេលវេលា (តម្លៃឡើងចុះ)។

ក្រុមហ៊ុនៈ បង្ហាញពូជ និងប្រភេទបន្លែដែលក្រុមហ៊ុនត្រូវការ ចំនួនបន្លែដែលក្រុមហ៊ុនត្រូវការក្នុង១ថ្ងៃ បង្ហាញពីទំរង់ចុះកិច្ចសន្យា ព្រមទាំងពិភក្សាគ្នារកចំណុចរួមដែលអាចទទួលយកបានទាំងសងខាងផងដែរ។

មកដល់ពេលនេះសហគមន៍កសិកម្មភូមិដប់បាត បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមាសបៃតង ដែលមានទីតាំងនៅភ្នំពេញក្នុងការផ្គត់ផ្គង់បន្លែសុវត្ថិភាព និងកំពង់ដំណើការទិញ លក់។

### ៧.សកម្មភាពផ្សព្វផ្សាយបន្លែសុវត្ថិភាពរបស់កសិករគោលដៅ

ចូលរួមរៀបចំការតាំងពិពរណ៍ផ្សារណាត់បន្លែ ផលិតផលសុវត្ថិភាព ជាមួយមន្ទីរកសិកម្មខេត្តបានមួយលើក និងជាមួយកម្មវិធីទិវាស្បៀងអាហារពិភពលោកនៅស្រុកកណ្តៀង១លើក ក្នុងគោលបំណងបង្កើនការយល់ដឹងពីបន្លែសុវត្ថិភាព ក្នុងចំណោមមហាជនទូទៅ និងជួយភ្ជាប់ទំនាក់ទំនងទីផ្សាររវាងអ្នកផលិតបន្លែ ជាមួយគ្រប់តួអង្គក្នុងខ្សែចង្វាក់ទីផ្សារ រួមមានអ្នកផលិត អ្នកលក់ដុំ អ្នកលក់រាយ និងអ្នកបរិភោគបន្លែ។

ក្នុងការតាំងពិពរណ៍ផ្សារណាត់បន្លែនេះ មានអ្នកបរិភោគជាច្រើន បានសាកសួរពីវិធីសាស្រ្តផលិត មានប្រើថ្នាំ និងជីគីមី ទីកន្លែងផលិត គាត់អាចរកទិញនៅកន្លែងណាបាន ហើយមានបន្លែប្រភេទអ្វីខ្លះ ចុះតម្លៃខុសគ្នាយ៉ាងម៉េច ដែរ អាចទាក់ទងជាមួយនណា ក្នុងទិវានេះក្រុមផលិតក៏បានយកបន្លែសុវត្ថិភាពមកតាំងលក់ផងដែរ មានអ្នកចាប់អារម្មណ៍ទាំងជិតឆ្ងាយ ប្រមូលទិញយកទៅតាមសេចក្តីត្រូវការរបស់គេម្នាក់ៗ។

### ៣. បញ្ហាប្រឈម និងការកែលម្អ:

- **ការអនុវត្តកសិកម្មល្អ (GAP) នៅមានកំរិត:** ដោយសារតែ ការយល់ដឹងរបស់កសិករ និងអ្នកបរិភោគនៅមិនទាន់យល់ពីគុណប្រយោជន៍នៃបន្លែសុវត្ថិភាពនៅឡើយ អ្នកផលិតគាត់នៅតែមានគំនិតថាប្រើកម្លាំងពលកម្មច្រើនតែលក់ស្មើនឹងតម្លៃបន្លែដែលប្រើថ្នាំគីមីដែរ សមាជិកក្នុងក្រុមមិនទាន់មានការឯកភាពគ្នា ដោយសារតែគាត់នៅតែគិតពីទីផ្សារទទួលទិញផលិតផលរបស់គាត់ ហើយអ្នកបរិភោគាត់នៅតថ្លៃ ឬគិតថាមិនមានអ្វីសំគាល់ថាបន្លែនោះគ្មានជាតិពុល។
- **មានភ្លៀងធ្លាក់ជោកជាំ និងជំនន់ទឹកភ្លៀង:** ធ្វើអោយរលួយខូចខាតដំណាំបន្លែរបស់កសិករ និងមានកសិករមួយចំនួនទៀតមិនអាចដាំបន្លែបាននៅរដូវវស្សា។
- **រាំងស្ងួតយូរអង្វែង:** ការរាំងស្ងួតយូរអង្វែងក៏ធ្វើអោយប៉ះពាល់ដល់ការដាំដំណាំខ្លាំង មានការលូតលាស់យឺត ប្រើកម្លាំងពលកម្មច្រើន ចំណាយពេលវេលាច្រើន និងធនធានច្រើនក្នុងការដាំដុះ ខ្វះទឹកស្រោចស្រព។
- **ដាំដំណាំតាមគ្នា:** កសិករមួយចំនួនធំនៅតែបន្តការដាំដំណាំបន្លែតាមគ្នា មិនបានអនុវត្តន៍តាមផែនការដាំដុះរបស់ក្រុម ធ្វើអោយតម្លៃបន្លែធ្លាក់ចុះខ្លាំង ហើយគាត់ថាអត់ទីផ្សារលក់បន្លែ។
- **ពូជបន្លែ និងថ្នាំសម្លាប់សត្វល្អិត**ៈ ពូជបន្លែមួយចំនួនដាំមិនសូវដុះ ដាំទៅអត់ផ្លែ ល្អតែដើម និងថ្នាំគីមីកសិកម្មភាគច្រើនមិនមានសរសេរជាអក្សរខ្មែរ ថ្នាំខ្លះប្រើទៅខូចដំណាំ ធ្វើអោយទិន្នផលដំណាំថយចុះទិន្នផល។
- **ការកត់ត្រា**ៈ: កសិករប្រហែល៥០%មិនបានកត់ត្រាសៀវភៅបានទៀងទាត់ទេ ដោយសារតែពួកគាត់មិនចេះអក្សរ ។
- សម្ភារៈដឹក និងស្តុកផលិតផលបន្លែៈ បន្លែសុវត្ថិភាព ទៀមទាអោយមានការប្រើប្រាស់សម្ភារៈក្នុងការវិចខ្ចប់ស្តុកផលិតផល រក្សារគុណភាពផលិតផល ពេលបន្លែលក់មិនអស់ ។

### ៤. ការសន្និដ្ឋានៈ

គម្រោងជំរុញផលិតកម្មស្បៀងដែលអនុវត្តន៍ដោយ អង្គការEPDO ក្រោមការគាំទ្ររបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញដល់កសិករដែលមានអាជិពជាអ្នកដាំបន្លែ និងផ្តល់ការគាំទ្រជាសម្ភារៈកសិកម្ម ពូជ និងឧបត្ថម្ភធន ដើម្បីពង្រីកការដាំដុះបន្លែរបស់កសិករ កាត់បន្ថយការនាំបន្លែចូលពីប្រទេសជិតខាង និងបង្កើនការដាំបន្លែសុវត្ថិភាព។

ក្នុងឆ្នាំ២០១៩នេះ គម្រោងបានគាំទ្រដល់កសិករផលិតបន្លែសុវត្ថិភាពបានចំនួន១៧០គ្រួសារ ក្នុងនោះបានរៀបចំជាក្រុមផលិតបន្លែសុវត្ថិភាពចំនួន១១ក្រុម ហើយក្រុមទាំងនោះយើងនិងពិនិត្យមើលក្រុមណាដែលមានសក្តានុពល និងរៀបចំបង្កើតទៅជាសហគមន៍កសិកម្មផលិតបន្លែបានចំនួន៣សហគមន៍ ហើយសហគមន៍កសិកម្មទាំងនេះទទួលបានការគាំទ្រការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មីៗ ការធ្វើបង្ហាញផ្ទាល់ ការណែនាំផ្ទាល់នៅតាមចំការបន្លែគ្រួសារនិមួយៗ លើគោលការការអនុវត្តកសិកម្មល្អ ការដឹកនាំ ការគ្រប់គ្រងក្រុម និងសហគមន៍កសិកម្ម និង

ទទួលបានការគាំទ្រជាសម្ភារៈកសិកម្ម ទុនសម្រាប់បម្រើលើផលិតកម្មដំណាំបន្លែ និងប្រើប្រាស់ជាទុនបង្វិលចូលក្រុមផលិត និងសហគមន៍កសិកម្ម។ ជួយសម្របសម្រួលទីផ្សារលក់បន្លែរបស់កសិករដូចជាៈ ទំនាក់ទំនងឈ្មួញអោយជួយទិញបន្លែ ផ្សព្វផ្សាយតាមគេហទំព័រ បណ្តាញសង្គមជាដើម និងចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនទិញបន្លែសុវត្ថិភាព។ ជាទូទៅEPDO បានអនុវត្តសកម្មភាពស្របទៅតាម គោលដៅនៃគម្រោងជំរុញសុវត្ថិភាពស្បៀង កសិករ ក្រុមផលិតមានក្តីរីករាយ សប្បាយចិត្តក្នុងការចូលរួមជាមួយគម្រោង និងទទួលបានជោគជ័យតាមការគ្រោងទុកគួរជាទីមោទនៈ។

## ៥. អនុសាសន៍

គម្រោងបានផ្តល់នូវភាពជោគជ័យនៃគោលដៅ និងគោលបំណងរួម របស់គម្រោង ដែលបានបង្កើតឡើងនៅក្នុងឯកសារគម្រោង។ ដោយមើលឃើញឥទ្ធិពលពីការអនុវត្តគម្រោងនេះ បានបង្ហាញថា អ្នកទទួលផល មានការរីកចំរើននូវសកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ តាមរយៈការទទួល បានធាតុចូលជាច្រើនដូចជា ជំនាញបច្ចេកទេស និងទុនគាំទ្រ សំរាប់ប្រកបមុខរបរ ហើយនិងជំនាញ ដែលបានរៀនសូត្រត្រូវបានអនុវត្ត ដែលជាផ្នែកមួយនៃការរកប្រាក់ចំណូលបន្ថែម សំរាប់គ្រួសារ។ ការងារនេះត្រូវបានធ្វើឡើងតាមរយៈ ការធ្វើឱ្យប្រសើរឡើងសមត្ថភាពនៃការប្រកបមុខរបរ និងទីផ្សារ ដើម្បីអាចឱ្យពួកគេលក់រួម ជាពិសេស ការធ្វើឱ្យប្រសើរឡើងជំនាញចរចារជាមួយនឹងឈ្មួញ។

កសិករបានធ្វើការដាំដំណាំចំរុះ រួមទាំងធ្វើឱ្យប្រសើរឡើង ការគ្រប់គ្រងធនធានធម្មជាតិ និងយល់ ដឹងពីការផ្លាស់ប្រែមួយចំនួនពីអតីតកាល។ កសិករស្វែងយល់ពីរបៀបភ្ជាប់បណ្តាញផលិតផល របស់ពួកគេ ទៅកាន់ទីផ្សារ។

កសិករមានការកើនឡើងចំណេះដឹង និងជំនាញ ក្នុងការធ្វើការជាមួយអ្នកពាក់ព័ន្ធ ជាពិសេសការ ចូលរួមសកម្មនៅក្នុងដំណើរការផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំ។ ចុងក្រោយ កសិករ អាចស្វែងរកតួអង្គអភិវឌ្ឍន៍សំខាន់ៗ ដើម្បីផ្តល់ការជួយគាំទ្រ ប្រសិនបើពួកគេត្រូវការ នៅពេលអនាគត ដែលមានការសម្របសម្រួលពីគម្រោងខ្លះ ឬក៏គ្មាន។

ការបង្កើតសហគមន៍កសិកម្ម គឺជាសញ្ញានិរន្តរភាព ដែលជាផ្នែកមួយនៃអង្គការបង្កើតអាជីវកម្មខ្លួនឯង។ គណៈកម្មការសហគមន៍កសិកម្ម មានការរីកចំរើនជំនាញ ក្នុងការចាត់ចែង និងដឹកនាំសមាជិក តាមភូមិនីមួយៗ របស់ពួកគេ។

មានកត្តាជោគជ័យជាច្រើន ប៉ុន្តែក៏មានបញ្ហាប្រឈមច្រើនដែរ នាពេលអនាគត ដែលត្រូវគ្រប់គ្រង និងចាត់ចែងអង្គការ ឬគម្រោងរបស់អង្គការ EPDO ដូចជា ការធ្វើឱ្យប្រសើរឡើងផលិតកម្មកសិកម្ម ទាក់ទងដីអត់មានជីវជាតិ និងការទទួលយកការផ្លាស់ប្តូរអាកាសធាតុ ស្វែងរកទីផ្សារសំរាប់លក់ផលិតផលរបស់ពួកគេ ខ្សែចង្វាក់ផលិតផលកសិកម្ម និងលើសពីនេះទៅទៀត ពីរបៀបគ្រប់គ្រងសហគមន៍កសិកម្ម ឱ្យមាននិរន្តរភាព ក្រោយពីគម្រោងត្រូវបានបញ្ចប់ដោយគ្មានការគាំទ្រ។

## ករណីសិក្សាទី១៖

# ការបន្សាំ ការប្រែប្រួលអាកាសធាតុ

គម្រោងជំរុញផលិតកម្មស្បៀងរបស់អគនាយកដ្ឋានកសិកម្មបានធ្វើការកែប្រែជីវភាពកសិករក្នុងដំបន់គោលដៅគម្រោងអោយមានជីវភាពប្រសើឡើងតាមរយៈការគាំទ្របច្ចេកទេស សម្ភារៈ ដើមទុនដាំដុះដំណាំ និងការសម្របសម្រួលទីផ្សារ របស់អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន ខេត្តពោធិ៍សាត់ ដែលអនុវត្តន៍នៅតំបន់គោល ដៅចំនួន២ស្រុក និង១ក្រុង គឺស្រុកភ្នំក្រវាញ ស្រុកបាកាន និងក្រុងពោធិ៍សាត់។ កាលពីដើមឆ្នាំ២០១៨ ភូមិបឹងឈូក ជាភូមិមួយដែលស្ថិតនៅក្នុង ឃុំខ្នាទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិនេះមាន ប្រជាជនភាគច្រើប្រកបរបរដាំដុះដំណាំបន្លែសំរាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ហើយត្រូវបាន EPDO ជ្រើសរើសជាភូមិគោលដៅសំរាប់អនុវត្តគម្រោងដែលមានកសិករស្ម័គ្រចិត្តចូលរួមជាសមាជិកក្រុមកសិករដាំបន្លែសុវត្ថិភាពចំនួន១២គ្រួសារ។



បងចាយ វាសនា អាយុ៣៩ឆ្នាំ មានប្រពន្ធឈ្មោះ ចាន់ ធី អាយុ៣០ឆ្នាំ មានកូនពីរនាក់ កូនស្រីម្នាក់អាយុ១៧ឆ្នាំ និងកូនប្រុសម្នាក់អាយុ១២ឆ្នាំ ជាគ្រួសារមួយក្នុងចំណោមគ្រួសារទាំង១២នៅក្នុងភូមិបឹងឈូក ដែលត្រូវបានជ្រើសរើសជាកសិករដាំបន្លែសុវត្ថិភាព ហើយបាន និងកំពុងអនុវត្តន៍ការដាំបន្លែតាមបច្ចេកទេសរយៈពេលជិតមួយឆ្នាំកន្លងមកហើយ។ កំពុងដំឡើងប្រព័ន្ធស្រោចស្រពបណ្តើរនិយាយបណ្តើរ បងប្រុស ចាយ វាសនា បាននិយាយអោយដឹងថា ពីមុនគាត់ក៏ជាអ្នកដាំបន្លែអាជីពដែរ តែដោយសារគ្មានជំនាញគាត់បានដាំចេះតែខាតព្រោះដាំមិនបានល្អ ដាំមិនដុះ រលួយ មានការបំផ្លាញពីសត្វល្អិត ដង្កូវ កើតជម្ងឺ ប្រមូលផលបានតិច និងមានរយៈពេលខ្លី ហើយក៏មិនដឹងយកទៅលក់នៅទីណាដែរ។ បងប្រុសបានរៀបរាប់បន្តថា ការបរាជ័យជារឿយៗបានធ្វើអោយគាត់ និងប្រពន្ធសម្រេចចិត្តឈប់ពីការដាំបន្លែ ហើយនាំគ្នាទៅធ្វើការនៅប្រទេសថៃអស់រយៈពេលជាច្រើនឆ្នាំ ក្រោយមក នៅពេលពួកគាត់មកលេងស្រុកនៅរដូវបុណ្យទានម្តងក៏បានឃើញបងប្រុសរបស់គាត់ ដាំបន្លែតាមបច្ចេកទេសជាមួយគម្រោងគាត់បានចាប់អារម្មណ៍ចង់ត្រឡប់មកដាំបន្លែវិញ។ បងប្រុសប្រាប់ថា ក្រោយពីត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញបានមួយឆ្នាំគាត់ក៏សម្រេចចិត្តឈប់ធ្វើការនៅប្រទេសថៃ ហើយនាំប្រពន្ធមកស្រុកវិញដើម្បីដាំបន្លែបន្តទៀតដោយនៅពេលនោះគាត់គ្រាន់តែរៀនសូត្រតាមបងប្រុស និងចូលរៀនជាមួយបុគ្គលិកអង្គការអ៊ីបដូ គ្រប់ៗវគ្គបណ្តុះបណ្តាលប្រចាំខែជារៀងរាល់ខែ ហើយអនុវត្តន៍ការដាំដោយមិនមានការគាំទ្រពីគម្រោងឡើយ។ បងស្រី ចាន់ ធី បានបន្ថែមថា ពីដំបូងឡើងគាត់មិនមានទំនុកចិត្តលើប្តីរបស់ខ្លួនឡើយ ព្រោះតែធ្លាប់បរាជ័យកន្លងមក តែដល់ពេលបានចូលរៀន និងជួយណែនាំផ្ទាល់នៅក្នុងចំការពីអ្នកជំនាញរបស់អង្គការអ៊ីបដូ ហើយពួកគាត់ខិតខំប្រឹងប្រែងដោយខ្លួនឯងផង ធ្វើអោយការដាំដុះរបស់គាត់ទទួលបានជោគជ័យជាបន្តបន្ទាប់ធ្វើអោយគាត់មានទឹកចិត្ត និងទំនុកចិត្តបន្តដាំទៀតរហូតដល់ពាក់កណ្តាលឆ្នាំ២០១៩ ទើបគ្រួសារបង ចាយ វាសនា បានចូលជាសមាជិកក្រុមដោយធ្វើការផ្លាស់ប្តូរជាមួយសមាជិកក្រុមចាស់ ដែលគាត់បានលាឈប់។ កំពុងពិនិត្យមើល







ផ្លែត្រឡាចបណ្ដើរបងស្រី ចាន់ ធី បានបន្តទៀតថា បច្ចុប្បន្នគាត់ និងប្ដីបានកំពុងដាំត្រឡាច និង ត្រប់បានយ៉ាងល្អ ព្រោះគាត់បានយល់ដឹងបានច្រើនទៅលើការដាំដំណាំតាមបច្ចេកទេសដូចជា ការបណ្ដុះកូន ការដាំ ការដាក់ជី បាញ់ថ្នាំ ស្គាល់អំពីបញ្ហាដែលកើតលើដំណាំដូចជា សត្វល្អិត និងដង្កូវបំផ្លាញ ជំងឺផ្សិត ការដាក់ទ្រើង ការលើករងការរៀបចំ និងកែប្រែគុណភាពដីដាំ និងយល់អំពីតម្រូវការទីផ្សារ ដែលធ្វើអោយគាត់អាចដាំ និងលក់បានប្រាក់ច្រើន ជាក់ស្ដែងក្នុងមួយថ្ងៃគាត់អាចលក់បន្លែបានពី ១៥០.០០០រៀល ទៅ ២០០.០០០រៀលដែលគាត់អាចផ្គត់ផ្គង់តម្រូវការក្នុងគ្រួសាររបស់គាត់បានយ៉ាងស្រួល ហើយសល់ប្រាក់ដើម្បីសន្សំទុកបានមួយចំនួនទៀតផង។

បងប្រុស ចាយ វាសនា និងប្រពន្ធពិតជាមានសេចក្ដីសប្បាយដែលបានចូលរួមជាមួយគម្រោង និងទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសដាំបន្លែពីបុគ្គលិកអង្គការEPDO ធ្វើអោយគាត់អាចរកប្រាក់ចំណូលបានដោយមិនចាំបាច់ចំណាកស្រុកទៅរកស៊ីនៅប្រទេសថៃទៀតទេ ហើយរស់នៅជួបជុំគ្នាជាមួយប្រពន្ធកូនដោយមានសុភមង្គល និងសូមថ្លែងអំណរគុណដល់ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន ដែលបានគាំទ្រដល់ក្រុមខ្ញុំ និងគ្រួសារខ្ញុំ ធ្វើឲ្យមានការផ្លាស់ប្ដូរទៅរកភាពរីកចម្រើនគួរជាទីពេញចិត្ត។

## ករណីសិក្សាទី២៖

# ភាពជឿជាក់លើការដាំបន្លែសុវត្ថិភាព

ភូមិដប់បាត ជាភូមិមួយដែលស្ថិតនៅក្នុង សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ភូមិនេះមាន ប្រជាជនភាគច្រើនប្រកបរបរដាំដុះដំណាំបន្លែសំរាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ភូមិនេះត្រូវបានជ្រើសរើសជាភូមិគោលដៅរបស់ អង្គការ EPDO សំរាប់អនុវត្តន៍ គម្រោងជំរុញផលិតកម្មស្បៀង ដែលទទួលជំនួយគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា អគនាយកដ្ឋានកសិកម្មកាលពីដើមឆ្នាំ២០១៨ ដែលមានកសិករស្ម័គ្រចិត្តចូលរួមជាសមាជិកក្រុម ដាំបន្លែសុវត្ថិភាពចំនួន៣0គ្រួសារ។ បងស្រី ឯក ចន្ថា អាយុ ៤១ ឆ្នាំ ប្តីឈ្មោះ ភី កំសត់ អាយុ៤៦ឆ្នាំ មានកូនក្នុងបន្ទុក៥នាក់ ស្រី១នាក់ គាត់មានរបរជាអ្នកដាំបន្លែ រស់នៅក្នុងភូមិដប់បាត សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានប្រកបរបរដាំដំណាំបន្លែចំរុះនេះ អស់រយៈពេលជិត៩ឆ្នាំមកហើយ លើផ្ទៃដីទំហំ១៥អា គ្រួសារបងស្រី ក៏ជាសមាជិកមួយក្នុងចំណោមគ្រួសារកសិករ៣0គ្រួសារ ដែលត្រូវបានជ្រើសរើសចូលជាសមាជិកក្នុងក្រុម ផលិតបន្លែសុវត្ថិភាព ហៅថាក្រុម ដប់បាតដែនដីបន្លែស្រស់ ហើយបានស្ម័គ្រចិត្តអនុវត្តន៍បច្ចេកទេស ដាំបន្លែសុវត្ថិភាព ក្នុងនោះគឺគាត់ដាំបន្លែចំរុះ។ ក្នុងសកម្មភាពប្រមូលផលបន្លែបណ្តើរ និយាយបណ្តើរ បង ស្រី ឯក ចន្ថា និងស្វាមី បានរៀបរាប់ប្រាប់ថា ពីមុនមកគាត់បានប្រ កបរបរដាំតែបន្លែធម្មតាតាមទំលាប់តាមរយៈការរៀនសូត្រពីអង្គការមួយចំនួន និងរៀនសូត្រតៗគ្នាខ្លះ ហើយមិនសូវមាន ការយល់ដឹងពីការប្រើប្រាស់ជី និងថ្នាំកសិម្ម ជាពិ សេសកម្រិតសុពលភាពជី ថ្នាំនូវពេលប្រមូលផលបន្លែដើម្បីលក់នៅទីផ្សារ។ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០១៨ គាត់បានចូលរួមជាមួយក្រុមផលិតបន្លែសុវត្ថិភាព (ដប់បាតរីកចម្រើន) ជាមួយអង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) ខេត្តពោធិ៍សាត់។ បច្ចុប្បន្ន បងស្រីកំពុងដាំដំណាំបន្លែប៉េងប៉ោះដីទំហំ៣អា ត្រប់ស្រួយទំហំដីដាំ២៨អា ត្រឡាចទំហំដីដាំ១២អា និងជីនាវង លើផ្ទៃដីទំហំ៣អា។ មុនចូលរួមគម្រោង ខ្ញុំមិនដែលឮ/ដឹង និង មិនស្គាល់ពាក្យថាបន្លែសុវត្ថិភាពទេ ខ្ញុំដាំបន្លែទៅតាមការប្រាប់តៗគ្នាពីឪពុងម្តាយ និងអ្នកជិតខាងដែលគាត់ធ្លាប់ធ្វើការដាំដុះ។ ការដាំដុះ តាមទំលាប់នេះ មានហានិភ័យខ្ពស់ដូចជា ការកើតជំងឺលើដំណាំការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ និងការបំផ្លាញ ពីសត្វល្អិតជាដើម មិនមានការយល់ដឹងច្បាស់ពីការប្រើប្រាស់ជី ថ្នាំកសិកម្ម ហើយប្រើប្រាស់តាមការយល់ដឹងតៗគ្នា មិនបានដឹងអំពីផលប៉ះពាល់ឡើយ។ បងស្រី បានបន្តទៀតថា ខ្ញុំបានចូលគម្រោងជំរុញផលិតកម្មស្បៀងនៅដើឆ្នាំ២០១៨ ក្រោយពីបានចូលជាសមាជិកក្រុមផលិតបន្លែសុវត្ថិភាពមក ថ្វីត្បិតតែការផលិតមានការលំបាកបន្តិចប៉ុន្តែខ្ញុំពេញចិត្ត ក្នុងការអនុវត្តន៍ ព្រោះខ្ញុំអាចទទួលបានការបណ្តុះបណ្តាលបន្ថែមពីគម្រោង កាន់តែច្បាស់អំពីការប្រើប្រាស់ថ្នាំពុល និងការគ្រប់គ្រងសត្វល្អិត បានកាត់បន្ថយហានីភ័យក្នុងការផលិត ហើយអាចទទួលបានទិន្នផលប្រសើងជាងមុន និងលក់បាន តម្លៃសមរម្យនៅលើទីផ្សារ គ្រួសារកសិករផ្សេងទៀតនៅក្នុងក្រុមបានទទួលស្គាល់ និងបានអនុវត្តន៌តាមបច្ចេកទេសធ្វើបានល្អ ហើយមានការពេញចិត្តក្នុងការអនុវត្តតាមបច្ចេកទេសបន្លែសុវត្ថិភាព។ គាត់បានបន្ថែមទៀតថា ខ្ញុំបានទទួលការបណ្តុះបណ្តាល និងបង្ហឹកបន្ថែមពីបុគ្គលិកអង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន(EPDO) ព្រមទាំងបានទទួលនូវសំភារៈកសិកម្មដូចជា: ប្រព័ន្ធដំណក់ទឹក សម្រាប់ផលិតកម្មបន្លែចំរុះ ដូច្នេះហើយខ្ញុំបាន ពង្រីកដីដាំ បន្ថែមចំនួន











0.75ហិតាមានដូចជា ប៉េងប៉ោះដីទំហំ៣អា ត្រប់ស្រួយទំហំដីដាំ២៨អា ត្រឡាចទំហំដីដាំ១២អា និងជីនាវងលើផ្ទៃដីទំហំ៣អា ឆ្នាំនេះខ្ញុំអាចបង្កើនទិន្នផលបន្លែបានច្រើនជាងមុន។ ដាក់ស្ពែងក្នុងផ្ទៃដី៩0អាគាត់បែងចែកជាពីរប្លុក ពាក់កណ្តាលរៀបចំដីបណ្តើរ ពាក់កណ្តាលប្រមូលផលបណ្តើរ បងស្រីបានបន្ថែមទៀតថា ពួកខ្ញុំតែងតែធ្វើរបៀបនេះដើម្បី អាចទទួលបានទិន្នផលវិលជុំក្នុងមួយឆ្នាំ២ទៅ៣ដង។



ខ្ញុំចាប់អារម្មណ៍ថា៖ បច្ចេកទេសថ្មី ដែលបានយកទៅអនុវត្តន៍ពិតជាបានជួយកាត់បន្ថយនូវជំងឺ ការបំផ្លាញពីកត្តាចង្រៃ ហើយដំណាំបន្លែមានការលូតលាស់ល្អ។ ប្រាក់ចំណូលដែលទទួលបានពីការប្រមូលផលបន្លែ ខ្ពស់ជាងមុន ខ្ញុំបានប្រើសម្រាប់ ផ្គត់ផ្គង់ក្នុងគ្រួសារ និង ពង្រីកមុខរបរបន្ថែម។ ខ្ញុំពិតជាមានក្តីសោមនស្សរីករាយព្រមទាំងពេញចិត្តជាខ្លាំងព្រោះគម្រោង ដែលបានជួយឲ្យគ្រួសារខ្ញុំមានចំណេះដឹង បច្ចេកទេសក្នុងការផលិតបន្លែសុវត្ថិភាពធ្វើឲ្យគ្រួសារគាត់មានការផ្លាស់ប្តូរទាំងជីវភាពរស់នៅ ឥរិយាបថ និងមានប្រាក់ចំណូលសមរម្យ មានថវិកាបំពេញតម្រូវការក្នុងគ្រួសារ និងសូមថ្លែងអំណរគុណដល់ រាជរដ្ឋភិបាលកម្ពុជា តាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន ដែលបានគាំទ្រដល់ក្រុមខ្ញុំ និងគ្រួសារខ្ញុំ ធ្វើឲ្យមានការផ្លាស់ប្តូរទៅរកភាពរីកចម្រើនគួរជាទីពេញចិត្ត។ គ្រួសារខ្ញុំនៅតែបន្តការផលិតបន្លែសុវត្ថិភាពដើម្បីបំពេញតម្រូវការគ្រួសារ និងទីផ្សារ។

# ៣. គម្រោង សន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

**Peace and Sustainable livelihood for All (PSL)**

គាំទ្រថវិកាដោយ

## ១ ពណ៌នាពីគម្រោង ឬកម្មវិធី

គម្រោងសន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា បានអនុវត្តនៅក្នុងភូមិគោលដៅចំនួន៦ ភូមិផ្ទះគ ឃុំអន្លង់វិល ភូមិផ្ទះស្រែ ឃុំស្វាយលួង ភូមិក្បាលឈើពុក ធ្លក ព្រៃស្រគុំ និងភូមិវត្តលៀប ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ តាមការចុះសម្របសម្រួល ការតាមដានត្រួតពិនិត្យ និងការសង្កេតផ្ទាល់ បានបង្ហាញថា ភូមិគោលដៅចំនួន៦ ទាំងអ្នកដឹកនាំ និងសមាជិកសហគមន៍បានធ្វើការផ្លាស់ប្តូរមួយចំនួនដូចខាងក្រោមៈ

អ្នកដឹកនាំសហគមន៍ មានសាមគ្គីភាព បង្កើតគំនិតផ្តួចផ្តើម ចូលរួមកៀរគធនធាន ក្នុងការអភិវឌ្ឍន៍សហគមន៍ មានទំនាក់ទំនងល្អទាំងខាងក្នុងនិងក្រៅសហគមន៍ មានការទទួលខុសត្រូវជាក់លាក់ មានការផ្លាស់ប្តូរការគិតដោយផ្តោតទៅលើការអភិវឌ្ឍន៍ដែលផ្អែកលើធនធានជាមូលដ្ឋាន ជាជាងការផ្តោតទៅលើបញ្ហា ឬការរង់ចាំទទួលតែជំនួយ។

សមាជិកសហគមន៍ មានការចូលរួមក្នុងដំណើរការអភិវឌ្ឍសហគមន៍ ចាប់តាំងពីពេលចាប់ ផ្តើមគម្រោង ការតាមដានត្រួតពិនិត្យ និងឆ្លុះបញ្ចាំងឡើងវិញ។ តាមរយៈការឆ្លុះបញ្ចាំងនេះសមាជិកសហគមន៍ម្នាក់ៗបានចូលរួមត្រួតពិនិត្យនូវលទ្ធផលដែលបានអនុវត្តកន្លងមក ចំណុចដែលធ្វើបានល្អ ចំណុចដែលបានអុវត្តខ្លះ និងចំណុចដែលមិនទាន់បានអនុវត្ត ព្រមទាំងចូលរួមធ្វើផែនការសម្រាប់រយៈពេល៦ខែបន្ត។ ក្នុងដំណើការនេះសមាជិកសហគមន៍បានដឹងអំពីពេលវេលា តួនាទី ការទទួលខុសត្រូវក្នុងការចូលរួមកែលម្អស្ថានភាពធ្វើឲ្យប្រសើរឡើងដើម្បីសម្រេចការរំពឹងទុករបស់ពួកគាត់។

EPDO បានយកចិត្តទុកដាក់ទៅលើការលើកកំពស់ស្ត្រីឲ្យចូលរួមរាល់សកម្មភាពរបស់គម្រោង ជាពិសេសការជ្រើសអ្នកដឹកនាំ អ្នកសម្របសម្រួលតែងតែផ្តល់ឱកាសអោយស្ត្រីឈរឈ្មោះធ្វើជាអ្នកដឹកនាំក្រុម/សហគមន៍ និងពង្រឹងបន្ថែមអំពីតួនាទី ការទទួលខុសត្រូវ ដើម្បីឲ្យពួកគាត់មានលទ្ធភាពធ្វើការសម្របសម្រួលក្នុងការអប់រំផ្សព្វផ្សាយអំពីអនាម័យសុខភាព ការត្រៀមបង្ការគ្រោះមហន្តរាយ ធ្វើបទបង្ហាញសម្រាប់ភ្ញៀវទស្សកិច្ចសិក្សា/សិក្ខាសាលាដៃគូរ សម្របសម្រួលកិច្ចប្រជុំក្រុម សម្របសម្រួលដំណើរការ ចុះបញ្ជីរ និងគ្រប់គ្រងបញ្ជីរក្រុមសន្សំ ការចលនាកៀរការចូលរួម របស់សមាជិកសហគមន៍ ដំណើរការនេះបានលើកទឹកចិត្តសមាជិកសហគមន៍ ជាពិសេសស្ត្រីចូលរួមយ៉ាងសកម្ម និងដោយសេរីនៅក្នុងដំណើរការរៀបចំផែនការ ការអនុវត្ត និងការតាមដាន។

គម្រោងបានគិត និងបញ្ចូលគំនិតយោបល់ ការបញ្ចេញមតិរបស់សមាជិកសហគមន៍រួមមានក្រុម បុរស ស្ត្រី កុមារ ជនពិការ ចាស់ជរា គណៈកម្មការផ្សេងៗ និងអាជ្ញាធរ តាមរយៈការប្រមូលព័ត៌មាន ការកសាងផែនការបញ្ចូលក្នុងផែនការវិនិយោគឃុំ ការសម្រេចចិត្ត ការរៀបចំគម្រោង សរសេរសំណើរ របាយការណ៍ តាមដានត្រួតពិនិត្យគម្រោងរៀងរាល់ត្រីមាស។ ការឆ្លុះបញ្ចាំងគម្រោង៦ខែម្តង អ្នកសម្របសម្រួលបានបែងចែកក្រុមពិភាក្សា ដូចជា



ក្រុមបុរស ស្ត្រី កុមារ ចាស់ព្រឹទ្ធាចារ្យ ពួកគាត់សុទ្ធតែបានបញ្ចេញនូវគំនិតយោបល់ល្អៗ ហើយគំនិតទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលនៃការឆ្លុះបញ្ចាំង និងការរៀបចំផែនការបន្ត។

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ អ្វីដែលEPDO បានយកចិត្តទុកដាក់ គឺការពង្រឹងសមត្ថភាពដល់គណៈកម្មការ ដែលមានស្រាប់នៅក្នុងភូមិគោលដៅទៅតាមលទ្ធផលនៃការប៉ាន់ប្រមាណសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ មានដូចជាភាពជាអ្នកដឹកនាំការងារជាក្រុម ការប្រាស្រ័យទាក់ទង វិធីសាស្ត្រដោះស្រាយទំនាស់។ល។ ជាពិសេសរំលឹកអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការសម្របសម្រួល ចាត់ចែង ដឹកនាំ ការកៀគធនធាន ក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនធ្វើឲ្យប្រជាជនមានទំនុកចិត្ត មានសាមគ្គីភាព និងរួមគ្នាលើកកំពស់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចគ្រួសារ និងសហគមន៍ឲ្យបានកាន់តែប្រសើរឡើង។

**តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង**

| ខេត្ត | ស្រុក | ឃុំ | ភូមិ | អ្នកចូលរួមក្នុងគម្រោង | | |
|---|---|---|---|---|---|---|
| | | | | គ្រួសារ | មនុស្សសរុប | ស្រី |
| ពោធិ៍សាត់ | កណ្ដៀង | ស្វា | ធ្លក | ១៧២ | ៨៥៧ | ៤៥៦ |
| | | | ព្រៃស្រគុំ | ១៤០ | ៥៥៣ | ២៨០ |
| | | | វត្តលៀប | ១៥៣ | | ៣១៩ |
| | | | ក្បាលឈើពុក | ៣១០ | ១៣១០ | ៦៨៣ |
| | | ឃុំស្វាយលួង | ភូមិផ្ទះស្រែ | ២៩៨ | ៨៧៨ | ៤៤៧ |
| | | ឃុំអន្លង់វិល | ភូមិផ្ទះគរ | ១០៨ | ៤៤០ | ២២៤ |
| | | ៣ ឃុំ | ៦ ភូមិ | ១១៨១ | ៤៦៩៣ | ២៤០៩ |

**គោលបំណងទី ១៖** ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋចំនួន ៥៤០ គ្រួសារ មនុស្សសរុប ៣៤៤០ នាក់ស្ត្រីចំនួន ១៧៣៣នាក់ តាមរយៈគំនិតផ្តួចផ្តើមប្រកបដោយចីរភាពដែលកសាងស្មារតីសហគមន៍នៅភូមិចំនួន ៦ ឃុំចំនួន៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

## ២ លទ្ធផលសំរេចបានរបស់គំរោង

### ក្រុមចិញ្ចឹមមាន់:

គម្រោងបានគាំទ្រក្រុមកសិករចិញ្ចឹមមាន់ ការវិនិយោគសម្ភារៈមានសំណាញ់ ពោងទឹក សម្រាប់ធ្វើទ្រុងមាន់តាមបច្ចេកទេសដោយចែកជា៤ប្លុក កសិករចំនួន៦០គ្រួសារក្នុងនោះនៅភូមិព្រៃស្រគុំ១០គ្រួសារ ធ្លក១០គ្រួសារ វត្តលៀប១០គ្រួសារ ក្បាលឈើពុក១០គ្រួសារ ផ្ទះគរ១០គ្រួសារ និងភូមិផ្ទះស្រែ១០គ្រួសារ បន្ទាប់ពីការការចងក្រងក្រុម EPDO បានគាំទ្របច្ចេកទេសចិញ្ចឹមមាន់តាមរយៈវគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សាក្រៅគម្រោង ក្នុងគម្រោង ដូចជា ការសាងសង់ទ្រុងមេពងខ័ណ្ឌជា៤ប្លុក ទ្រុងមានសាច់១ប្លុក ទ្រុងកូនមាន់ទើបញាស់ ការធ្វើចំណី ការធ្វើអនាម័យ ការថែទាំ



និងវិធានការការពារជម្ងឺសត្វ។ល។ តាមរយៈនៃការចុះតាមដាន និងបង្ហឹកបាននង្ហាញថា ក្នុងចំណោមកសិករចំនួន ២៦៦គ្រួសារ កំពុងដំណើរការចិញ្ចឹមមាន់តាមបច្ចេកទេស មានទ្រុងមាន់ដេក ទ្រុងដើរ មានទ្រុងបំបែកកូន មានអនាម័យជីវៈសុវត្ថិភាពសម្រាប់ការលើកកម្ពស់ការចិញ្ចឹមមាន់។ មិនតែប៉ុណ្ណោះគ្រួសារទាំងនេះបានចែករំលែកបទពិសោធន៍ការចិញ្ចឹមមាន់តាមបច្ចេកទេសដល់គ្រួសារផ្សេងទៀតក្នុងភូមិចំនួន៦៨គ្រួសារ។ តាមសំដីអ្នកស្រីប៊ិច តាំងលី រស់នៅភូមិធ្លក ឃុំស្បា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ បាននិយាយថាការចិញ្ចឹមមាន់តាមបច្ចេកទេស បានកាត់បន្ថយនូវជម្ងឺ និងអត្រាស្លាប់របស់មាន់ និងធ្វើឲ្យគ្រួសារខ្ញុំតាំងពីចូលជាកសិករចិញ្ចឹមមាន់គម្រូ គាត់បានចិញ្ចឹមមាន់តាមបច្ចេកទេស ព្រមទាំងបានដាំត្រកួនសម្រាប់ជាចំណីមាន់ គ្រួសារគាត់ទទួលបានប្រាក់ចំណូលពីការលក់កូនមាន់ចំនួន១២៦ក្បាល បានទឹកប្រាក់៦៥០.០០០៛ លក់មាន់សាច់បានចំនួន៧៧០.០០០៛។ ប្រាក់ចំណូលនេះពួកគាត់ប្រើប្រាស់ទៅលើការទិញសម្ភារៈ សម្លៀកបំពាក់សិក្សាកូន ទិញស្បៀងអាហារ សម្រាប់ពង្រីកមុខរបរ និងបំពេញតម្រូវការផ្សេងៗក្នុងគ្រួសារ។

**ក្រុមដាំបន្លែ:**

EPDOបានផ្តល់វគ្គបណ្តុះបណ្តាល ពង្រឹង និងបង្ហឹកបន្ថែមដល់គ្រួសារដាំបន្លែអំពីបច្ចេកទេស មានដូចជាការប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិត ការធ្វើរងបន្លែតាមរដូវកាល បានចំនួនក្នុងអំឡុងរបាយការណ៍បីឆ្នាំនេះ EPDOបានធ្វើការបណ្តុះបណ្តាលដល់គ្រួសារដាំបន្លែ រៀនសូត្រពីបច្ចេកទេស(ទស្សនកិច្ចសិក្សា) ដាំបន្លែ នៅភូមិអូរច្លូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ដែលជាភូមិគោលដៅរបស់អង្គការEPDOរបស់គម្រោងជម្រុញផលិតកម្មស្បៀង ក្នុងគោលបំណងៈដើម្បីឲ្យកសិករដែលបានចូលរួម ទទួលបានវិធីសាស្រ្តការដាំបន្លែ ភាពជោគជ័យដែលទទួលបានពីការដាំបន្លែ ឧបសគ្គ បញ្ហាដែលកសិដ្ឋានដាំបន្លែជួបប្រទះ និងដំណោះស្រាយដល់ក្រុមគោលដៅចំនួន២២ក្រុម សមាជិកក្រុមចំនួន៥២គ្រួសារ ក្នុងនោះភូមិធ្លក១២គ្រួសារ ព្រៃស្រគុំ១១គ្រួសារ វត្តលៀប៥គ្រួសារ ក្បាលឈើពុក៨គ្រួសារ ភូមិថ្នះស្រែ១៥គ្រួសារ និងភូមិថ្នះគរ១គ្រួសារ គ្រួសារទាំងនោះកំពុងអនុវត្តបច្ចេកទេសនៃការដាំបន្លែមានស្ពៃស ត្រកួន ត្រប់ សណ្តែកគួរ ននោង ស្ពៃខ្មៅ ពោត ត្រឡាច ត្រសក់ ទទួលបានប្រាក់ចំណូលពីការដាំបន្លែបានប្រសើរជាងមុន។ ជាក់ស្តែងគ្រួសារប្អូនស្រី តុប គឹមលាង រស់នៅភូមិវត្តលៀប កំពុងដាំត្រសក់តាមបច្ចេកទសបានចំនួន១២រង ក្នុងមួយរងៗមានប្រវែង២៧ម៉ែត្រ ដោយរៀបប្រព័ន្ធតំណក់ទឹក មានក្រាលកៅស៊ូផ្លាស្ទិក មានសំណាញ់ទ្រើង និងដាំពោត មកដល់ពេលនេះគាត់បានប្រមូលផលពោតបានលក់បានថវិកាចំនួន៧៨០,០០០រៀល ត្រសក់បានថវិកាចំនួន៥៤០,០០០រៀល ហើយកំពុងបេះបន្តជារៀងរាល់ថ្ងៃ ប្រាក់ចំណូលទាំងនេះគាត់បានយកទៅពង្រីកការដាំបន្លែបន្ថែមទៅលើការទិញសម្ភារៈ ពូជបន្លែ ថ្នាំផ្សិត និងមួយចំណែកសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ។គ្រួសារគាត់កំពុងភ្ជួរហាលដីតាមបច្ចេកទេសសម្រាប់ដាំស្ពៃសក្រញាំញ់បន្ថែមទៀត មិនតែប៉ុណ្ណោះគ្រួសារនេះបានចែករំលែកបច្ចេកទេស ដល់កសិករដាំបន្លែផ្សេងទៀតចំនួន១៨នាក់ ស្រី១៣នាក់(ស្រីពិការ១នាក់) ពីបច្ចេកទេសធ្វើដី ចាក់រង ការរៀបប្រពន្ធ័ដំណក់ទឹក ក្រាលកៅស៊ូផ្លាស្ទិក ជាកន្លែងគម្រូការប្រើជីគីមី ការប្រើថ្នាំពុល វិធីសាស្រ្តថែរក្សា និងកាពារជម្ងឺដែលកើតមានលើបន្លែផងដែរ។





**កសិករចិញ្ចឹមមាន់គម្រូ:**

EPDO បានវិនិយោគសម្ភារៈសម្រាប់សាងសង់ទ្រុងមាន់ដល់គ្រួសារចិញ្ចឹមមាន់ចំនួន១២ក្រុម ចំនួន២៤គ្រួសារ នៅភូមិធ្លក៤គ្រួសារ ព្រៃស្រគុំ៥គ្រួសារ ភូមិវត្តលៀប៤គ្រួសារ ភូមិក្បាលឈើពុក៤គ្រួសារ ភូមិផ្ទះស្រែ៤



គ្រួសារ និងភូមិផ្ទះគរ៣គ្រួសារ។ ក្នុងការអនុវត្តការចិញ្ចឹមមាន់តាមបច្ចេកទេស មានប្លុកទ្រុងមេពង ទ្រុងមាន់សាច់ ទ្រុងកូនមាន់ មានដាំបន្លែនៅជិតទ្រុង មានពាងទឹក ស្នូកចំណី តាមទ្រុងនៃគ្រួសារនីមួយៗមានមេមាន់២០ក្បាល បា៥ក្បាល ទ្រុងកូនមាន់តូចចំនួន២ទ្រុង កូនជំទង់ ១ទ្រុង និងទ្រុងមេពងមានចំនួន៤ប្លុក ហើយមាន់មានការរីកធំធាត់ ព្រមទាំងមានសុខភាពល្អ ពួកគាត់កំពុងទទួលបានប្រាក់ចំណូល ក្នុងនោះកសិករទទួលចំណូលពីការលក់កូនមាន់មានចំនួន១៤គ្រួសារ ថវិកាជាមធ្យមក្នុងមួយគ្រួសារចន្លោះ៤០០,០០០រៀល ទៅ៦០០,០០០រៀល ហើយមានកូនមាន់សម្រាប់ចិញ្ចឹមធ្វើមាន់សាច់ផងដែរ។ គ្រួសារចិញ្ចឹមមាន់គម្រូ២គ្រួសារ បានចែករំលែកបទពិសោធន៍ការចិញ្ចឹមមាន់តាមបច្ចេកទេសដល់ក្រុមគោលដៅមកអង្គការដៃគូចំនួន១៩នាក់ និងសមាជិកក្រុមដាំបន្លែEPDOចំនួន១៩នាក់។

**ភ្នាក់ងារសុខភាពសត្វភូមិៈ**



គម្រោងបានធ្វើការពង្រឹងសមត្ថភាពដល់ភ្នាក់ងារសុខភាពសត្វភូមិ ក្នុងនោះភ្នាក់ងារសុខភាពសត្វភូមិចំនួន៥នាក់ នៅក្នុងភូមិគោលដៅទាំង៦ភូមិ ចុះប្រឹក្សាយោបល់តាមគ្រួសារចិញ្ចឹមសត្វអំពីការធ្វើវ៉ាក់សាំង ការថែទាំ ការពារជម្ងឺ ដល់សត្វមាន់ គោ ក្របី ជ្រូក គ្រួសារចំនួន៨១៦គ្រួសារបាន និងកំពុងប្រើប្រាស់សេវាសុខភាពសត្វ មិនតែប៉ុណ្ណោះពួកគាត់មានការសហការគ្នា សាមគ្គីភាព ប្រឹក្សាយោបល់ជាមួយសមាជិកសហគមន៍ រួមចំណែកក្នុងការដោះស្រាយបញ្ហាសុខភាពសត្វតាមភូមិគោលដៅ ដើម្បីបង្កើនមានការគ្រប់គ្រងថែទាំសត្វក្នុងសហគមន៍ បានប្រសើរជាងមុន ។

**គោលចំណងទី២៖** ដើម្បីលើកកម្ពស់សុខភាពអនាម័យ និងសុខភាពសហគមន៍ចំនួន ៥៤០ គ្រួសារ មនុស្សសរុប ៣.៤៤០នាក់ ស្ត្រីចំនួន ១.៧៣៣នាក់ តាមរយៈការអប់រំការវិនិយោគលើទឹកស្អាត និងអនាម័យនៅតាមភូមិចំនួន៦ ឃុំចំនួន៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។



អង្គការEPDOធ្វើការដើម្បីធានាថាសហគមន៍អាចទទួលបានសុខភាពល្អ ដោយផ្តោតទៅលើអនាម័យ និងទឹកស្អាត។ ប្រជាជនទទួលបានទឹកស្អាត និងការអប់រំពីសារៈសំខាន់ ការអនុវត្តន៍អនាម័យ ជាវិធីចំណាយដ៏មានប្រសិទ្ធភាពដើម្បីសម្រេចបានលទ្ធផលពិតប្រាកដសម្រាប់សុខភាព។ តាមរយៈកម្មវិធីអប់រំផ្សព្វផ្សាយ និងការរៀបចំទិវាអនាម័យតាមសហគមន៍ និងសាលារៀន គឺជាផ្នែកមួយសំខាន់ នៃកម្មវិធីលើកកំពស់អនាម័យជនបទ ទិវាលាងដៃនៅសហគមន៍ និងសាលារៀន ដែលមានឥទ្ធិពលជំរុញឲ្យសហគមន៍មានការភ្ញាក់រលឹក ចូលរួមលើកកម្ពស់អនាម័យ យល់ពីប្រភពនៃការចម្លងរោគ ព្រមទាំងធ្វើការផ្លាស់ប្តូរឥរិយាបទ ដោយធ្វើអនាម័យតាមគ្រួសារជាប្រចាំ ដូចជាសំអាតផ្ទះ ភូមិឋាន ចំណីអាហារ សំលៀកបំពាក់ពេលគឺអនាម័យនាំមុខដោយសហគមន៍.សកម្មភាពមួយចំនួនដែលជួយជម្រុញសហគមន៍ឲ្យមានសុខភាពល្អមានដូចជាៈ

**ទិវាអនាម័យបរិស្ថាន**

គម្រោងបានធ្វើការសហការជាមួយអ្នកស្មគ្រ័ចិត្តសុខភាពភូមិក្នុងការប្រមូលសមាជិកសហគមន៍ ដើម្បីពួកគាត់ចូលរួមធ្វើទិវាអនាម័យ បរិស្ថាន បាន១លើកនៅភូមិទាំង៦ និងសាលារៀនចំនួន៤ នៅក្នុងតំបន់គោលដៅ សមាជិកចូលរួមចំនួនប្រជាពលរដ្ឋចំនួន៣៦០នាក់ ស្រី២៤០នាក់ ទិវានេះអនុវត្តនៅតាមគ្រួសារចំនួន២រី៣គ្រួសារជាគម្រូសម្រាប់សហគមន៍ និងសាលារៀនចំនួន៤ គឺសាលារៀនទួលតាព្រហ្ម ក្បាលឈើពុក ផ្ទះគរ និងសាលារៀនផ្ទះស្រែ រួចធ្វើការឆ្លុះបញ្ចាំង/ប្រៀបធៀបពីអត្ថប្រយោជន៍នៃការសម្អាត បរិស្ថានដល់ប្រជាពលរដ្ឋទាំង៦ភូមិ និងកុមារតាមសាលាទាំង៤។ យើងសង្កេតឃើញថា ប្រជាពលរដ្ឋប្រមាណ២០០គ្រួសារកំពុងអនុវត្តការបោសសម្អាតបរិស្ថានជុំវិញផ្ទះជាប្រចាំ និង១៦០គ្រួសារទៀតមិនទាន់បានអនុវត្តជាប្រចាំនៅឡើយ បុគ្គលិកEPDOសហការជាមួយអ្នកស្មគ្រ័ចិត្តសុខភាពភូមិចុះបង្ហឹកតាមគ្រួសារបន្ថែមទៀត ធ្វើយ៉ាងណាអោយពួកគាត់មានការផ្លាស់ប្តូរទម្លាប់ប្រសើជាងមុន ដើម្បីកាត់បន្ថយជម្ងឺផ្សេង។

## កម្មវិធីសហគន៍ដឹកនាំអនុវត្តអនាម័យ(CLTS)



សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ គឺជាផ្នែកមួយសំខាន់ នៃកម្មវិធីលើកំពស់អនាម័យជនបទ ដែលមានឥទ្ធិពលជំរុញឲ្យសហគមន៍មានការភ្ញាក់រលឹក ចូលរួមលើកកម្ពស់អនាម័យ ជាពិសេសការប្រើប្រាស់បង្គន់អនាម័យនៅតាមគ្រួសារប្រកប ដោយនិរន្តភាព។ គ្រប់ការងារទាំងអស់ ដើម្បីសម្រេចបានជោគជ័យចាំបាច់ត្រូវតែកំណត់យុទ្ធវិធី ឬជំហានដែលជាឧបករណ៍សម្រាប់ធ្វើសកម្មភាពឲ្យបានច្បាស់ លាស់ក្នុងការឆ្លើយតបការលើកកម្ពស់កម្មវធីសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ CLTS ប្រកបដោយប្រសិទ្ធភាព។ EPDOបានធ្វើការសហការជាមួយគ្រូបង្រៀនតាមសាលារៀន អាជ្ញាធរ និងប្រជាពលរដ្ឋដែលស្ថិតនៅតំបន់គោលដៅ ចូលរួមកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ(CLTS)ចំនួន១លើក នៅសហគមន៍ចំនួន៦ភូមិ និង៤សាលារៀន ចំនួន២លើក អ្នកចូលរួមសរុបចំនួន២៩៦៣នាក់ ស្រី១៥៤៥នាក់ក្នុងនោះ(សហគមន៍ចំនួន១,៧០៦នាក់ ស្រី១,០៩៨នាក់ កុមារា៤៩០នាក់ កុមារី៤៤០នាក់ បុរសពិការ១០នាក់ ស្រីពិការ៧នាក់) នៅក្នុង ក្រោយពីធ្វើCLTSចំនួន៦ភូមិប្រជាពលរដ្ឋចំនួន៥០០គ្រួសារបានចូលមកចុះឈ្មោះក្នុងបញ្ជីរផែនការសាងសង់បង្គន់។

## ទិវាអនាម័យដឹកនាំដោយកុមារ



អង្គការEPDOបានសម្របសម្រួលកុមារនៅសាលារៀន និងនៅសហគមន៍ដឹកនាំធ្វើទិវាអនាម័យ នៅសាលាបឋមទាំង៤ក្នុងភូមិគោលដៅ និងសហគមន៍ក្នុងភូមិគោលដៅទាំង៦ គឺភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ផ្ទះស្រែ ភូមិផ្ទះគរ និងសាលាចំនួន៤គឺសាលាទួលតាព្រហ្ម សាលាក្បាលឈើពុក សាលាផ្ទះគរ និងសាលារៀនផ្ទះស្រែ អ្នកចូលរួមសរុប១,០៣២នាក់ ស្រី៦១០នាក់ ក្នុងនោះ(សមាជិកសហគមន៍៣៨៤នាក់ស្រី២៧៩នាក់ កុមារា៣១៥នាក់ កុមារី៣២៣នាក់ គណៈកម្មការចំនួន១៧នាក់ ស្រី៦នាក់ ស្ត្រីពិការ២នាក់ ។ តាមរយៈការជួបជាមួយក្រុមកុមារ និងក្រុមគណៈកម្មការ បានបង្ហាញឲ្យឃើញថា សមាជិកសហគមន៍ចំនួន៣៤៥គ្រួសារបានផ្លាស់ប្តូរទម្លាប់របស់ពួកគេបង្កើតមានសំភារៈ សម្រាប់ដាក់សំរាមតាមគ្រួសារ ហើយយល់ដឹងអំពីការរាលដាល និងការការពារជំងឺដែលបណ្តាលមកពីការចោលសម្រាមពាសវាលពាសកាលនៅជុំវិញផ្ទះ ភូមិដ្ឋាន។ គ្រូបង្រៀននៅសាលារៀនទាំង៤បានរៀបចំធុងសម្រាប់សិស្សដាក់សម្រាម ហើយសិស្សចំនួន៤១២នាក់ស្រី២១៨នាក់បានចោលសម្រាមក្នុងធុងសម្រាមនៅសាលាទាំង៤ ហើយពួក

គេនឹងបន្តទម្លាប់នេះដល់ ប្អូនៗរបស់ពួកគេនៅផ្ទះ ដែលជាកត្តានាំមុខ ឪពុក ម្តាយ អាណាព្យាបាល នៅក្នុងសហគមន៍មានអនាម័យល្អប្រសើរ។

## យុទ្ធនាការអនាម័យសម្រាប់សហគមន៍ និងទិវាលាងដៃសាលារៀន



គម្រោងបានអនុវត្តទិវាលាងដៃក្នុងគោលបំណងបង្កើនចំណេះដឹងព្រមទាំងធ្វើអោយប្រសើរឡើងនូវសុខភាពអនាម័យសម្រាប់កុមារ និងសមាជិកសហគមន៍ ទិវានេះធ្វើក្រោយកម្មវិធីCLTSព្រោះដើម្បីឆ្លើយតបនូវការធ្វើឲ្យប្រសើរឡើងផ្នែកសុខភាពគឺផែនការសាងសង់បង្គន់ និងការលាងដៃដើម្បីកាត់បន្ថយពីប្រភពនៃការចម្លងរោគទាំង៤មាន រុយ ដៃ បន្លែ និងទឹក គម្រោងអនុវត្ត២លើក នៅសាលាបឋមសិក្សាចំនួន៤ និងសហគមន៍៦ភូមិចំនួន៥លើក អ្នកចូលរួមសរុប ៣៩១៣នាក់ ស្រី១៧២៦នាក់ ក្នុងនោះ(កុមារា៨៩០នាក់ កុមារី១០៥៧នាក់ សមាជិកសហគមន៍សរុប១១៧៥នាក់ ស្រី៦៦៥ នាក់នៅក្នុងភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ភូមិផ្ទះស្រែ និងភូមិផ្ទះគរ ពួកគាត់មានការផ្លាស់ប្តូរទម្លាប់ ដោយសំអាតអនាម័យទូទៅ និងលាងដៃមុនទទួលទានអាហារបានល្អប្រសើរជាងមុន។

## សាងអាងទឹកភ្លៀង



គម្រោងបានវិនិយោគអាងត្រងទឹកភ្លៀងចំនួន១០០អាង នៅភូមិគោលដៅចំនួន៥គឺភូមិធ្លក២៥គ្រួសារ ក្បាលឈើពុក២២គ្រួសារ ភូមិព្រៃស្រគុំ១៧គ្រួសារ វត្តលៀប១៦គ្រួសារ និងភូមិផ្ទះស្រែ២០គ្រួសារ)សមាជិកចំនួន១០០គ្រួសារ សមាជិកគ្រួសារ៥៥៣នាក់ មានអាងដាក់ទឹកសម្រាប់ប្រើប្រាស់ ហូប ងូត ជាពិសេសមានទឹកសម្រាប់ដាំហូបក្នុងគ្រួសារ ដែលជាការកាត់បន្ថយពេលវេលា កាត់បន្ថយគ្រោះថ្នាក់ដោយសារការទៅរកទឹករបស់ស្ត្រី ហើយជាពិសេសកុមារមានទឹកសម្រាប់យកទៅហូបនៅសាលារៀន។

## សកម្មភាពសាងសង់បង្គន់អនាម័យ



ក្រោយពីធ្វើ CLTS ព្រមទាំងផែនការសាងសង់បង្គន់តាមភូមិនីមួយៗរួចមក អង្គការEPDOបានធ្វើការឆ្លើយតបការសាងសង់បង្គន់អនាម័យដោយមានការចូលរួមវិនិយោគថវិកាពីសហគមន៍មួយគ្រួសារ៥០ដុល្លារ បង្គន់សាងសង់រួចចំនួន៣១០គ្រួសារ (គ្រួសារចូលរួមបដិភាគ២៥៥គ្រួសារ គ្រួសារក្រីក្រសាងសង់ជូន១០០%ចំនួន៥៥គ្រួសារ) ក្នុងនោះ(ភូមិធ្លក៧៦គ្រួសារ (ក្រីក្រ៤គ្រួសារ) ភូមិព្រៃស្រគុំ៣៦គ្រួសារ (ក្រីក្រ៤គ្រួសារ) វត្តលៀប៤២គ្រួសារ(ក្រីក្រ១២គ្រួសារ) ក្បាលឈើពុក៧៧គ្រួសារ (ក្រីក្រ៥គ្រួសារ) ភូមិផ្ទះគរ៣៤គ្រួសារ(ក្រីក្រ២១គ្រួសារ) និងភូមិផ្ទះស្រែ៤៥គ្រួសារ(ក្រីក្រ៩គ្រួសារ)) ក្នុងតម្លៃបង្គន់មួយ១៦០ដុល្លារ ដោយលើកលែងនូវការចូលរួមបដិភាគ។ ក្រោយពីការសាងសង់បង្គន់រួចមក សមាជិកចំនួន១១០គ្រួសារមានបង្គន់ប្រើប្រាស់សមរម្យ ជាពិសេសមានបង្គន់សម្រាប់ភ្ញៀវមកចូលរួមកម្មវិធីផ្សេង(បុណ្យ ការកូន) ជាក់ស្តែងតាមសម្តីអ្នកស្រី សូត្រ ផានី ដែលជាសមាជិកភូមិបាននិយាយថាបង្គន់ដែលបានសាងសង់នៅពេលនេះបានជួយសម្រួលដល់អ្នកភូមិក្នុងការសុំអនុញ្ញាតិច្បាប់ ធ្វើបុណ្យ ការកូនតាមប្រពៃណី ព្រមទាំងមានបង្គន់សម្រាប់ភ្ញៀវ ប្រើប្រាស់បានស្រួលជាងមុន។

**គោលចំណងទីបី:** ដើម្បីលើកកម្ពស់យន្តការសុវត្ថិភាពសង្គមចំនួន៥៤០គ្រួសារ មនុស្សសរុប៣.៤៤០នាក់ស្រី ១.៧៣៣នាក់ តាមរយៈការផ្សព្វផ្សាយការកសាងសន្តិភាព និងភាពជាម្ចាស់របស់សហគមន៍នៅភូមិចំនួន៦ ឃុំចំនួន ៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

## អប់រំផ្សព្វផ្សាយអំពីការកសាងសន្តិភាព



មុនពេលធ្វើការអប់រំផ្សព្វផ្សាយ EPDOបានធ្វើការប៉ាន់ប្រមាណពីអំពើហឹង្សា លទ្ធផលបានបង្ហាញថានៅក្នុងភូមិគោលដៅទាំង៦ មានអំពើហឹង្សាចំនួន ១៨គ្រួសារ បន្ទាប់ពីបានលទ្ធផលEPDO បានផ្សព្វផ្សាយអំពីការកសាងសន្តិភាព ច្បាប់អំពើហឹង្សា និងផលប៉ះពាល់ដោយសារអំពើហឹង្សា តាមភូមិចំនួន៦ភូមិ (ភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ផ្ទះស្រែ និងភូមិផ្ទះគរ) ដើម្បីឲ្យសមាជិកគ្រួសារ និងសហគមន៍ចេះមានសាមគ្គីភាព ចេះជួយទុក្ខធុរៈគ្នាក្នុងគ្រាមានអាសន្ន និងការចូលរួមក្នុងកិច្ចការសង្គមផ្សេងៗ ដែលមានអ្នកចូលរួមសរុបចំនួន១៣៧០គ្រួសារ សមាជិកសហគមន៍សរុប៣៤៤៦នាក់ ស្រី១៧៥០នាក់ គណៈកម្មការ៥៣នាក់ ស្រី១៧នាក់មានការៈ




១.កើនឡើងនូវចំណេះដឹងអំពីការកសាងសន្តិភាពហើយពួកគេបានប្តេជ្ញាចិត្តកាត់បន្ថយអំពើហឹង្សា។

២.ភាពសុខដុមរម្យនាក្នុងគ្រួសារជាពិសេសកុមារ និងស្រ្តី

៣.សន្តិភាពនៅក្នុងគ្រួសារ និងសហគមន៍ ការសាមគ្គីភាព ការជួយទុក្ខធុរៈគ្នា មានការសហការកើនឡើងនូវការយល់ដឹងអំពីតួនាទីបុរស ស្រ្តី ក្នុងគ្រួសារ និងសហគមន៍មានភាពប្រសើរជាងមុន ។

៤.ពួកគាត់មានការយល់ដឹងអំពីផលប៉ះពាល់នៃអំពើហឹង្សា ហើយករណីអំពើហឹង្សាបានថយចុះនៅក្នុងភូមិគោលដៅចំនួន៦ភូមិដែលយើងបានធ្វើការ។

## ពង្រឹងសមត្ថភាពដល់គណៈកម្មការអំពីភាពជាអ្នកដឹកនាំ



EPDOបានពង្រឹងសមត្ថភាព ដល់មេដឹកនាំសហគមន៍ចំនួន៥លើក ៦សហគមន៍ ស្មើនឹង៩៤នាក់ ស្រី៣៨នាក់(ពិការ៣នាក់ ស្រី២នាក់) អំពីភាពជាអ្នកដឹកនាំកម្រិតសហគមន៍ ការគ្រប់គ្រង ការងារជាក្រុម និងការដោះស្រាយទំនាស់។ ក្នុងចំណោមគណៈកម្មការចំនួន៩៤នាក់ភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ឃុំស្យា ភូមិផ្ទះស្រែ ឃុំស្វាយលួង និងភូមិផ្ទះគរ ឃុំអន្លង់វិល ដែលបានទទួលវគ្គពង្រឹងសមត្ថភាព មាន៥០នាក់ ស្រី១៥នាក់មានភាពសកម្ម បរិច្ចាកពេលវេលាដើម្បីអភិវឌ្ឍន៍សហគមន៍ មានសមត្ថភាព ការដឹកនាំ ចាត់ចែង ថែទាំ សមិទ្ធិផលដែលបានវិនិយោគ មានការសហការគ្នា សាមគ្គីភាព មានការគ្រប់គ្រង ដឹកនាំ ចាត់ចែង បែងចែកការទទួលខុសត្រូវ បង្កើតគំនិតផ្តួចផ្តើម ចូលរួមកៀរគរធនធានក្នុងការអភិវឌ្ឍន៍សហគមន៍ មានទំនាក់ទំនងល្អទាំងខាងក្នុង និងក្រៅសហគមន៍ មានការទទួលខុសត្រូវជាក់លាក់ មានការផ្លាស់ប្តូរការគិត ដោយផ្តោតទៅលើការអភិវឌ្ឍន៍ដែលផ្អែកលើធនធានជាមូលដ្ឋាន កាត់បន្ថយការផ្តោតទៅលើបញ្ហា ឬការពឹងពាក់ទៅលើជំនួយពីខាងក្រៅ ៖

## គម្រោងគំនិតផ្តួចផ្តើមរបស់សហគមន៍

EPDOបានចុះសិក្សាស្ថានភាពពាក់ព័ន្ធនឹងជីវភាពរស់នៅ និងកត្តាប្រឈមនានា តាមរយៈកិច្ចប្រជុំភូមិ ដែលមានការចូលរួមពីមេភូមិភូមិ ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋទូទៅក្នុងភូមិធ្លក ភូមិព្រៃស្រគុំ ភូមិវត្តលៀប ឃុំស្បា ភូមិថ្នះស្រែ ឃុំស្វាយលួង និងភូមិថ្នះគរ ឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ លទ្ធផលបានបង្ហាញថាប្រជាពលរដ្ឋនៅក្នុងភូមិធ្លក ជួបការលំបាកដូចជា សាលារៀននៅឆ្ងាយពីភូមិសិស្សពិបាកក្នុងការធ្វើដំណើរទៅសិក្សា ស្បៀងហូបមិនគ្រប់គ្រាន់ ខ្វះទឹកប្រើប្រាស់ និងស្រោចស្រពស្រូវស្រែ និងដំណាំបន្លែ ជារឿយៗគ្រោះធម្មជាតិ ទឹកជំនន់ និងភាពរាំងស្ងួតតែងតែកើតមានជារៀងរាល់ឆ្នាំ ធ្វើអោយខូចផលដំណាំ បន្លែ ស្រូវ និងសត្វចិញ្ចឹមជាដើម។ល។ ទឹកគឺជាតម្រូវការចម្បងរបស់ពួកគាត់សម្រាប់លើកកំពស់ផលិតកម្មកសិកម្ម ដូចនេះទាំងអ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ បានផ្តួចផ្តើមស្តារប្រឡាយទឹក ដោយពួកគាត់បានស្នើឡើងថាប្រឡាយទឹក បានផ្តល់ផលប្រយោជន៍ជាច្រើនសម្រាប់វិស័យកសិកម្មដូចជា ធ្វើស្រែប្រាំង ស្រែបង្កើនរដូវ ស្រោចស្រប់ដាំបន្លែនៅក្នុងសហគមន៍របស់ពួកគាត់ ។ ដោយជួបស្ថាភាពបែបនេះ សហគមន៍បានផ្តួចផ្តើគំនិតដើម្បីស្វែងរកការគាំទ្រនូវតម្រូវការរបស់ពួកគេ ជាលទ្ធផលពួកគាត់បានទទួលការគាំទ្រមួយចំនួនដូចខាងក្រោម៖

### **១.ការសាងសង់សាលារៀនមួយខ្នងបីបន្ទប់**



គណៈកម្មការសាលា មាតាបីតា សមាជិកសហគមន៍ បានផ្តួចផ្តើមគំនិតក្នុងការរៃអង្គាសថវិកាពីសមាជិក សប្បុរសជន ធ្វើបានគ្រឹះសាលា១ខ្នង៣បន្ទប់ រួចពួកគេក៏បានដាក់សំណើមកEPDO ដើម្បីសុំជំនួយសាងសង់ផ្នែកខាងលើដើម្បីឲ្យសិស្សមានលទ្ធភាពក្នុងការសិក្សាជិតផ្ទះ។ EPDO ក៏បានគាំទ្រគំនិតផ្តួចផ្តើមរបស់ពួកគេ ក្នុងដំណើការសាសង់អាជ្ញាធរឃុំអន្លង់វិលបានបង្កើតគណៈកម្មការត្រួតពិនិត្យការសាងសង់សាលា ហើយពួកគាត់បានធ្វើការតាមដានការសាងសង់ ពិនិត្យលើសម្ភារៈ ដែក និងការរៀបពុម្ពចាក់សសរសរ រៀងរាល់ការត្រួតពិនិត្យ តាមបញ្ជីសម្ភារៈដែលបានចុះកិច្ចព្រមព្រៀង ពួកគាត់កត់បញ្ចូលក្នុងសៀវតាមដាន រួចផ្តល់អនុសាសន៍កឬសម្រួលនូវចំនុចខ្វះចន្លោះរបស់ជាង មកដល់ពេលនេះសាលាសាងសង់១ខ្នង៣បន្ទប់ទំហំ២១មx៩មx៤ម នៅភូមិថ្នះគរបានសាសង់បញ្ចប់ជាស្ថាពរ ហើយសិស្សក៏បានចូលសិក្សាផងដែរ។

### **២.គម្រោងស្តារប្រឡាយទឹកចំនួន៤ខ្សែ**



**២.១.ស្តារប្រឡាយមួយខ្សែភូមិវត្តលៀប**ប្រវែង១៣០០មXមាត់លើ២មxបាតក្រោម១មxកម្ពស់១.៥ម គម្រោងនេះបានជួយគាំទ្រដល់ប្រជាពលរដ្ឋចំនួន១៧៦គ្រួសារ ភូមិព្រៃស្រគុំ៣០គ្រួសារ ភូមិស្បា២០គ្រួសារដី អាចស្រោចស្រប់លើផ្ទៃដីស្រែ១៥០ហិចតា បច្ចុប្បន្នពួកគាត់មានទឹកសម្រាប់ប្រើប្រាស់ ស្រោចស្រប់ដំណាំស្រូវ ដំណាំរួមផ្សំ បន្លែ និងការចិញ្ចឹមសត្វផងដែរ។

**២.២.ប្រឡាយមួយខ្សែភូមិថ្នះស្រែ**៖ប្រវែង៥៩០មXមាត់លើ៤មxបាតក្រោម២មxកម្ពស់២ម បានបំពេញនូវតម្រូវការទឹដល់អ្នកភូមិថ្នះស្រែ១៥០គ្រួសារ អាចស្រោចស្រប់ដីស្រែ៦៥ហិចតា ដំណាំរួមផ្សំ បន្លែ និងការចិញ្ចឹមសត្វ។



**២.៣.ប្រឡាយមួយខ្សែភូមិក្បាលឈើពុក**៖ស្តារប្រឡាយ២ខ្សែប្រវែង១០៤០មXមាត់លើ២មxបាតក្រោម១មxកម្ពស់១ម បានឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ

ចំនួន២៣០គ្រួសារ ផ្ទៃដី២៤០ហិចតា(នៅភូមិក្បាលឈើពុកមាន១៥០គ្រួសារ ផ្ទៃដីស្រែសរុប១៦០ហិចតា ភូមិត្រពាំងថ្ម៨០គ្រួសារ ផ្ទៃដីស្រែសរុប៨០ហិចតា។



**២.៤.ស្តារអាងស្តុកទឹកភូមិកោះក្រសាំង:** គម្រោងបានវិនិយោគថវិកា ដោយមានការចូលរួមបដិភាគពីសហគមន៍ស្តារអាងស្តុកទឹកមួយកន្លែងនៅភូមិកោះក្រសាំង ឃុំអន្លង់វិល មានទំហំ៧០០មXមាត់លើ៨ម×បាតក្រោម៤ម×កម្ពស់៣មអាងមួយកន្លែងស្តុកទឹក សម្រាប់កសិករដាំបន្លែ និងធ្វើស្រែ បានចំនួន២៦៩គ្រួសារ មនុស្សសរុប១០៨០នាក់ ស្រី៥៦៨នាក់ ស្ត្រីជាមេគ្រួសារ៥២នាក់ ជនពិកា១០នាក់ ស្រី៧នាក់ ចាស់ជរា៣៩នាក់ ស្រី២៥នាក់ដីស្រែសរុប៨៦៩ហិចតា ក្នុងនោះ (ភូមិកោះក្រសាំង៨៧គ្រួសាដីស្រែ១២៣ហិចតា ភូមិព្រៃកតាគង់៦៤គ្រួសាដីស្រែ៩០ហិចតា ភូមិជ័យជំនះ១១៨គ្រួសាដីស្រែ៤៦៣ហិចតា)។ ពួកគាត់ទាំងនោះមានទឹកសម្រាប់ដាំបន្លែ ដំណាំស្រូវ និងចិញ្ចឹមសត្វ។ មិនតែប៉ុណ្ណោះគណៈកម្មការបានអំពាវនាវកៀរធនធានដល់សប្បុរសជនមកអភិវឌ្ឍន៍បង្គោលភ្លើងនៅតាមដងអាងស្តុកទឹក សម្រាប់កសិករដាក់ម៉ូទ័រទាញទឹកមកស្រោចស្រប់បន្លែ ដំណាំផងដែរ។

តាមស្ថានភាពខាងលើអ្នកដឹកនាំសហគមន៍ អាជ្ញាធរមូល សមាជិកសហគមន៍ បានផ្តួចផ្តើមសាងសង់លូជ្រុងកាត់ផ្លូវចំនួនមួយកន្លែងដែលមាន មុខការកាត់២ម៉ែត្រ បណ្តោយ៦ម៉ែត្រ និងកម្ពស់១.៥ម៉ែត្រ ដើម្បីជាផ្លូវថ្នល់សម្រួលដល់ការធ្វើដំណើររបស់សហគមន៍ចំនួន៣ឃុំ និង១១ភូមិ (ឃុំស្រែស្តុកចំនួន៤ភូមិ ឃុំកោះជុំចំនួន៣ភូមិ និងឃុំស្វាយលួង ចំនួន៤ភូមិ សមាជិកសហគមន៍សរុប១.៣០៨គ្រួសារ មនុស្សសរុបចំនួន៧.១៣៨នាក់ ស្រី៣.២៦០នាក់) ក្នុងនោះ បុរស១១២៨នាក់ ស្ត្រី១១៥០នាក់ កុមារ១៥៣០នាក់ ស្រី៨៥០នាក់ យុវជន១១៥០នាក់ ស្រី១២៦០នាក់ ជនងាយរងគ្រោះ៦០នាក់ ជនពិការ១០នាក់ ចាស់ជរា៧នាក់។ ព្រមទាំងជាលូបង្ហូរទឹកពីប្រឡាយម្ខាងទៅម្ខាងទៀត សម្រាប់សង្គ្រោះស្រូវនៅផ្នែកខាងក្រោមនៃផ្លូវថ្នល់ផងដែរ។

**៣. ការសន្និដ្ឋាន:**

គម្រោងគម្រោង ***សន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា*** ដែលអនុវត្តន៍ដោយអង្គការEPDO ឧបត្ថម្ភដោយអង្គការ Australia Catholic Relief/Caritas Australia (ACR/CA) បានជំរុញដល់កសិករដែលបានចូលរួមក្នុងគម្រោង ក្នុងការបង្កើនផលិតកម្មកសិកម្ម (ចិញ្ចឹមសត្វ ដាំបន្លែ ធ្វើស្រ...) និងការផ្សារភ្ជាប់ទីផ្សារ និងជាពិសេសការធ្វើជំនួញ គំនិតអាជីវកម្មដែលមានទំនុកចិត្តជាងមុន។

ក្នុងឆ្នាំ២០១៩នេះ គម្រោងបានគាំទ្រដល់កសិករផលិតបន្លែសុវត្ថិភាពបានចំនួន៥៤០ គ្រួសារ ក្នុងនោះបានគាំទ្រដល់ក្រុមផលិតបន្លែ ក្រុមចិញ្ចឹមសត្វ ធ្វើស្រែ ក្រុមជំនួញខ្នាតតូច ក្រុមទាំងនេះ បានទទួលការគាំទ្រការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មថ្មីៗ ការធ្វើបង្ហាញផ្ទាល់ ការណែនាំផ្ទាល់នៅតាមចំការបន្លែ ចិញ្ចឹមសត្វ គ្រួសារនិមួយៗលើគោលការការអនុវត្តកសិកម្មល្អ ការដឹកនាំ ការគ្រប់គ្រងក្រុម និងសហគមន៍ និងទទួលបានការគាំទ្រជាសម្ភារៈកសិកម្ម ទុនសម្រាប់បម្រើលើផលិតកម្មដំណាំបន្លែ និងចិញ្ចឹមសត្វ ប្រើប្រាស់ជាទុនបង្វិលចូលក្រុមផលិត។ ជួយសម្របសម្រួលទីផ្សារលក់បន្លែ និងមាន់របស់កសិករដូចជាៈ ទំនាក់ទំនងឈ្មួញ ទិញបន្លែ មាន់ ជាពិសេសប្រព័ន្ធទំនាក់ទំនងទីផ្សារជាមួយអ្នកប្រមូលទិញ។ ជាទូទៅEPDO បានអនុវត្តសកម្មភាពស្របទៅតាម គោលដៅនៃគម្រោង ***សន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា*** កសិករ ក្រុមផលិតមានក្តីរីរាយ សប្បាយចិត្តក្នុងការចូលរួមជាមួយគម្រោង និងទទួលបានជោគជ័យតាមការគ្រោងទុកគួរជាទីមោទនៈ។

## ករណីសិក្សាទី១

# ស្តីពី
# ការដាំបន្លែតាមបច្ចេកទេសធ្វើឲ្យកើនប្រាក់ចំណូលក្នុងគ្រួសារ





លោក លី ចន្ធី ភេទប្រុសអាយុ៣៦ឆ្នាំ ប្រពន្ធឈ្មោះ តុប គឹមលាង អាយុ៣០ឆ្នាំ មានសមាជិកសរុប៤នាក់ ស្រី១នាក់ (កូន២នាក់ស្រី០នាក់) រស់នៅភូមិវត្តលៀប ឃុំស្វា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ តាមសម្ដីអ្នកស្រី តុប គឹមលាង បានរៀបរាប់ប្រាប់ថា មុនពេលចូលក្នុងគម្រោងគ្រួសារខ្ញុំ មានមុខរបរធ្វើស្រែ ដាំបន្លែតាមទម្លាប់បន្តិចបន្តួចមាន ត្រសក់ ស្ពៃមើម ស្ពៃស ចំពោះការបន្លែទាំងនេះជួបនឹងឧបសគ្គជាច្រើនដូចជារលួយ ក្រហមស្លឹក រួញដៃ ដង្កូវស៊ី ចៃនៅលើស្លឹក ត្រឹងស៊ីមើម ក្នុងមួយវដ្តនៃការដាំបន្លែខ្ញុំទទួលបានប្រាក់ចំណូលចំនួនពី៣០,០០០រៀលទៅ៥០,០០០រៀល និងហូបក្នុងគ្រួសារបន្តិចបន្តួច។ រីឯប្តីខ្ញុំគាត់ធ្វើជាកូនជាងផ្ទះម្តងម្កាល និងធ្វើសំណង់ ប្រាក់ចំណូលរបស់គាត់ទទួលបានតិចតួចគ្រាន់ទូរទាត់ជាមួយអាហារ និងសាំងជិះប្រចាំថ្ងៃស្ទើរតែអស់ សល់ថវិកាបន្តិចបន្តួចចូលក្នុងគ្រួសារ។ ប្រាក់ចំណូលពួកខ្ញុំទាំងពីរនាក់មិនអាចផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារបានឡើយ។ នៅខែសីហាឆ្នាំ២០១៨ គ្រួសារខ្ញុំបានចូលជាសមាជិកក្រុមដាំបន្លែ ពួកខ្ញុំទទួលបានវគ្គបណ្តុះបណ្តាល/បង្វឹក និងទស្សនកិច្ចសិក្សាស្តីអំពីបច្ចេកទេសនៃការដាំបន្លែ ម្យ៉ាងទៀតគ្រួសារខ្ញុំបានរៀនសូត្រផ្ទាល់ពីកសិករគម្រូនៅភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដែលជាភូមិគោលដៅរបស់អង្គការ **EPDO** នៃគម្រោងជម្រុញផលិតកម្មស្បៀង ស្តីពីការដាំបន្លែតាមបច្ចេកទេសមានដូចជាការភ្ជួររាស់ដី ការបាចកំបោរលើដី ការលើករង ចន្លោះរងពីមួយទៅមួយ ការដាក់បង្គោលទ្រើង វិធីសាស្ត្រចោះរន្ធដាក់កូន ការធ្វើដីបណ្តុះកូន ប្រើជីការជ្រើសរើសពូជបន្លែតាមរដូវកាល វិធានការកំចាត់សត្វល្អិត វិធីសាស្ត្រប្រើថ្នាំពុលកសិកម្ម និងការថែទាំ។ ខ្ញុំមានការចាប់អារម្មណ៍ ក៏ធ្វើផែនការដាំបន្លែ ហើយទទួលបានការវិនិយោគជាថវិកាចំនួន២០៤០,០០រៀល។ គ្រួសារខ្ញុំចាប់ផ្តើមដាំត្រសក់ ពោត ស្ពៃក្រញ៉ាញ់ តាមបច្ចេកទេសដោយប្រើប្រព័ន្ធដំណក់ទឹក បច្ចុប្បន្នគ្រួសារខ្ញុំប្រមូលផលបន្លែត្រសក់ជារៀងរាល់ព្រឹកក្នុងមួយព្រឹកបេះបានចំនួន៥០គីឡូទៅ៧០គីឡូ មកដល់ពេលនេះប្រាក់ចំណូលក្នុងមួយវដ្តនៃបន្លែត្រសក់បានចំនួន១,១០០,០០០រៀល គ្រួសារខ្ញុំកំពុងប្រមូលផលបន្ត។ រីឯការប្រមូលផលពីដំណាំពោតទទួលបានប្រាក់ចំណូលចំនួន៦០០.០០០រៀល ចំណែកឯបន្លែស្ពៃស/ក្រញាញ់ កំពុងមានការលូតលាស់តែមិនទាន់បានប្រមូលផល។ ប្រាក់ចំណូលទាំងនេះខ្ញុំប្រើប្រាស់ទៅលើ ការទិញសម្ភារៈពង្រីកការដាំបន្លែ ទិញសម្ភារៈពង្រីកការចិញ្ចឹមមាន់តាមបច្ចេកទេស ម្ហូបអាហារប្រចាំថ្ងៃ ចំណាយលើសម្ភារៈសម្លៀកបំពាក់សិក្សារបស់កូន ចំណាយលើបុណ្យ ការមួយចំណែកទៀតសម្រាប់សន្សំក្នុងគ្រួសារ សន្សំក្រុមប្រចាំសប្តាហ៍។ បច្ចុប្បន្ននេះគ្រួសារខ្ញុំកំពុងបន្តការដាំជាលក្ខណៈបង្វិលជុំ ព្រមទាំងមានផែនការដាំជាប់ជានិច្ច។ លើសពីនេះទៅទៀតការដាំបន្លែរបស់គ្រួសារខ្ញុំក្លាយទៅជាកន្លែងគម្រូសម្រាប់កសិករក្នុងភូមិ និងភូមិដទៃទៀតមករៀនសូត្រទៀតផង។ ប្អូនស្រីតុប គឹមលាង បាននិយាយប្រាប់បន្តទៀតថា គ្រួសារខ្ញុំមានការសប្បាយរីករាយព្រមទាំងពេញចិត្តចំពោះគម្រោង មានការកើនឡើងទាំងចំណេះដឹង បច្ចេកទេស ធនធានសម្ភារៈ ការផ្លាស់ប្តូរទម្លាប់ដាំស្របតាម




បច្ចេកទេស ចេះកែច្នៃពេលវេលា ប្រើប្រាស់ធនធានដែលមានស្រាប់ឲ្យអស់លទ្ធភាព ព្រមទាំងមានការកើនឡើងនូវប្រាក់ចំណូលធ្វើឲ្យជីវភាពគ្រួសារប្រសើរជាងមុន ។ មិនតែប៉ុណ្ណោះគម្រោងបានធ្វើឲ្យប្តីរបស់ខ្ញុំមានការផ្លាស់ប្តូរមុខរបរពីលក់កម្លាំងពលកម្មបែរមកដាំបន្លែ ដោយក្តីរីករាយពេញចិត្ត និងមានសុភមង្គលល្អក្នុងគ្រួសារ។ ទន្ទឹមនឹងនោះគ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការ**EPDO** និងអង្គការ **ACR/ Caritas Australia** ដែលបានជួយបណ្តុះគំនិត បច្ចេកទេស និងវិនិយោគ សម្ភារៈបង្កើនមុខរបរ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្តូរ និងរីកចម្រើនគួរជាទីពេញចិត្ត។

# ករណីសិក្សាទី២
# ស្តីពី
# ភាពជោគជ័យរបស់គ្រួសារទូរភ្ញាស់ពងមាន់នៅភូមិឆ្លក






លោក នួន ម៉ឺន ភេទប្រុសអាយុ២៩ឆ្នាំ ប្រពន្ធឈ្មោះ គួន ស៊ីលាភ ភេទស្រី អាយុ២៨ឆ្នាំ មានសមាជិកសរុប ៤នាក់ស្រី២នាក់ ក្នុងនោះកូនប្រុស១នាក់ កូនស្រី១នាក់ រស់នៅភូមិឆ្លក ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ប្អូនស្រីគួន ស៊ីលាប បាននិយាយថា គ្រួសារខ្ញុំចូលគម្រោងចិញ្ចឹមមាន់ជាមួយអង្គការEPDO តាំងពីខែកក្កដាឆ្នាំ២០១៧មកម្ល៉េះ ហើយគ្រួសាររបស់ខ្ញុំទទួលបានវគ្គបណ្តុះបណ្តាល/បង្វឹកបច្ចេកទេស ទស្សនៈកិច្ចសិក្សា អំពីការចិញ្ចឹមមាន់តាមបច្ចេកទេស ការប្រើប្រាស់វ៉ាក់សាំង និងទទួលបានការវិនិយោគជាថវិកាចំនួន១៧៨ដុល្លារ ខ្ញុំចិញ្ចឹមមាន់តាមបច្ចេកទេសមានដូចជា ទ្រុងមេពងចំនួន៤ប្រឡោះ ទ្រុងមាន់សាច់២ប្រឡោះ ចាប់ផ្តើមពីមាន់បាចំនួន៤ក្បាល មាន់មេពងចំនួន២០ក្បាល។ តាំងឆ្នាំ២០១៧ដល់សីហាឆ្នាំ ២០១៨ គ្រួសារខ្ញុំទទួលបានប្រាក់ចំណូលពីការលក់មាន់សាច់ចំនួន៤០ក្បាលបានថវិកាចំនួន១លានរៀល និងលក់កូនមាន់ចំនួន៧០០ក្បាល ទទួលបានថវិកា២លាន៨សែនរៀល។ ដោយឃើញការចិញ្ចឹមមាន់ទទួលបានជោគជ័យបណ្តើរៗ គម្រោងជដែកពិភាក្សានូវការបន្ថែមមុខរបរគឺទូរភ្ញាស់ពងមាន់ ដោយធ្វើផែនការ មានការពង្រឹងសមត្ថភាពស្តីពីបច្ចេកទេសភ្ញាស់ពងមាន់ ផែនការពង្រីកមេមាន់ពង និងបាមាន់បន្ថែម។

លុះដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ គ្រួសារខ្ញុំចូលរួមបដិភាគចំនួន៥៣ដុល្លារជាមួយអង្គការEPDO ទទួលបានទូរភ្ញាស់ពងមាន់មួយគ្រឿងទំហំ៣៥៨ពង មានចំនួន៥ថាស ក្នុងមួយថាសមានចំនួន៨៨ពង ចាប់ផ្តើមពង្រីកមាន់មេពងបន្ថែមរហូតដល់ចំនួន៧០ក្បាល បាមាន់ចំនួន១២ក្បាល។ គ្រួសារខ្ញុំចំណាយដីទទឹង១៥ម៉ែត្រ បណ្តោយ២០ម៉ែត្រដាំត្រកួន និងដាំដើមឆៃយ៉ាជុំវិញរបងភូមិសម្រាប់ផ្សំចំណីមាន់ រីឯប្តីរបស់ខ្ញុំ លែងជួលស្រែគេមកធ្វើ ព្រោះចំណូលពីការធ្វើស្រែបានតិចជាងប្រាក់ចំណូលការចិញ្ចឹមមាន់ ម្យ៉ាងវិញទៀតដោយយោលទៅលើស្ថានភាពជាក់ស្តែងគ្រោះធម្មជាតិកើតឡើង គឺទឹកបានរីងស្ងួតមិនអាចតម្រូវឲ្យធ្វើស្រែនៅ រដូវប្រាំងច្រើនបានឡើយ ហេតុនេះហើយបានជាប្តីខ្ញុំបែរមកជួយការងារចិញ្ចឹមមាន់វិញ ចំណែកមុខរបរធ្វើស្រែ ធ្វើបន្តិចបន្តួចសម្រាប់យកស្រូវហូបក្នុងគ្រួសារតែប៉ុណ្ណោះ។





តាំងពីខែតុលា២០១៨មក គ្រួសារខ្ញុំចំណាយសម្រាប់ដំណើរការទូរភ្ញាស់មានការប្រើប្រាស់ភ្លើងសម្រាប់ទូរភ្ញាស់ និងអំពូលកំដៅកូនមាន់រយៈពេល៦ខែអស់ថវិកា២៤០ពាន់រៀល ចំណីយកមកផ្សំជាមួយបន្លែចំនួន៥៤០គីឡូអស់ថវិកា១លានរៀល ចំណាយកន្ទក់ ចុងអង្ករ ស្រូវ ថ្នាំសម្រាប់ផ្សំជាចំណីធម្មជាតិអស់ថវិកា២លាន៧សែនរៀល និងចំណាយលើការទិញវ៉ាក់សាំងអស់ថវិកាចំនួន៨ម៉ឺនរៀល សរុបការចំណាយក្នុងរយៈពេល៦ខែអស់ថវិកាចំនួន៤លាន១សែនរៀល។ ទន្ទឹមនឹងនោះ ទូរភ្ញាស់ពងមាន់ជោគជ័យក្នុងការភ្ញាស់បាន៩៣% ហើយគ្រួសារខ្ញុំទទួលបានប្រាក់ចំណូលពីការលក់កូនមាន់ជាជំហានដំបូង ឲ្យប្រជាពលរដ្ឋក្រៅភូមិគោលដៅបានចំនួន៩៦០ក្បាល និងលក់កូនមាន់ឲ្យប្រជាពលរដ្ឋក្នុងភូមិគោលដៅបានចំនួន៩៦៩ក្បាល ក្នុងតម្លៃមួយក្បាល៤០០០រៀល ទទួលបានប្រាក់ចំណូលចំនួន ៧,៧១៦,០០០រៀល ។ ក្នុងរយៈពេល៦ខែនេះគ្រួសារខ្ញុំទទួលបានប្រាក់ចំណូលពីការលក់កូនមាន់ និងមាន់សាច់សរុបទាំងអស់ចំនួន១១.១៩៦.០០០រៀល ប្រាក់ចំណេញពីការលក់កូនមាន់ និងមាន់សាច់បានចំនួន៧.០៩៦.០០០រៀល។ ប្រាក់ចំណូលទាំងអស់នេះពួកខ្ញុំប្រើប្រាស់ដូចជា ចាក់ដីបំពេញទីធ្លាផ្ទះចំនួន២០០ឡានអស់ថវិកាចំនួន ៣,៤០០,០០០រៀល ចំណាយសន្សំប្រាក់ប្រចាំសប្តាហ៍ ជាមួយក្រុមសន្សំដើម្បីផ្លាស់ប្តូរ សន្សំក្នុងគ្រួសារ ផ្គត់ផ្គង់ម្ហូបអាហារប្រចាំថ្ងៃសម្រាប់កូនទាំងពីរ។ បច្ចុប្បន្នគ្រួសារមានម៉ូតូចំនួន២គ្រឿងម៉ាកហុងដាសេរី២០១៥មួយគ្រឿង និងម៉ាកសង់កូរេសម្រាប់ដឹកឥវ៉ាន់មួយគ្រឿង ហើយពួកខ្ញុំកំពុងមានផែនការទិញទូរភ្ញាស់ពងមាន់បន្ថែមមួយគ្រឿងទៀត។

ប្អូនស្រីបាននិយាយប្រាប់ថា ខ្ញុំមានការសប្បាយរីករាយព្រមទាំងពេញចិត្តជាខ្លាំងចំពោះគម្រោង ដែលបានជួយឲ្យគ្រួសារខ្ញុំមានចំណេះដឹង មានបច្ចេកទេសភ្ញាស់ពងមាន់ ចិញ្ចឹមមាន់ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្តូរទាំងជីវភាពរស់នៅ ឥរិយាបថ និងមានប្រាក់ចំណូលសមរម្យ មានថវិកាបំពេញតម្រូវការក្នុងគ្រួសារ។ គ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការEPDO និងម្ចាស់ជំនួយ ACR/ Caritas Australia ដែលបានជួយបណ្តុះគំនិត ផ្តល់បច្ចេកទេស និងវិនិយោគថវិកាសម្រាប់បង្កើនមុខរបរ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្តូរ រីកចម្រើនគួជាទីពេញចិត្ត។